# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្វាង ឈឹងហ៊្វ** ជនជាតិចិន សញ្ជាតិចិន កើតនៅក្រុងហ្គាងតុង ប្រទេសចិន ៧៧៨៦

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩៩ ស្តីពីការតែងតាំងលោក **តុង សេង** ជា **ឧកញ៉ា** ៧៧៨៧

១៧-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០២ ស្តីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** ជូនមេបញ្ជាការ និង មេបញ្ជាការរង របស់យោធភូមិភាគទី ៧ និង ទី ៩ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន ០៣ រូប ៧៧៨៨

១៧-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៣ ស្តីពី :

-ការបញ្ឈប់តំណែងឯកឧត្តម **សំ សុខ** ជាទីប្រឹក្សាសម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី

- តែងតាំងឯកឧត្តម **ស៊ីន ម៉េងស្រ៊ុន** ជាទីប្រឹក្សាសម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួស ឯកឧត្តម **សំ សុខ** ៧៧៨៩

១៩-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៥ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះមន្ត្រីជាន់ខ្ពស់ នាយទាហាន នាយនគរបាល និងសប្បុរសជនដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិ មាតុភូមិ ចំនួន ៣២ រូប ៧៧៩០

១៩-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៧ ស្តីពីការតែងតាំងឯកឧត្តម **លី សំអាន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកទូរគមនាគមន៍អន្តរជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ៧៧៩២

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១០ ស្តីពីការប្រោសព្រះរាជទានចំពោះលោកជំទាវ **ម៉ែន គន្ធី ហុក ឡុងឌី** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៧៧៩៣

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១១ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **ចៅ តិរុណ** នូវគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ៧៧៩៤

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១២ ស្ដីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៤ រូប ៧៧៩៥

## II-ក្រុមប្រឹក្សាធម្មនុញ្ញ

២៩-១២-២០០៥ -សេចក្ដីសម្រេចលេខ ០៧៣/០០៥/២០០៥ កបធ.ច ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ៧៧៩៦

## III-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៧-១២-២០០៥ -អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្ដីពីសម្បទានដីសេដ្ឋកិច្ច ៧៧៩៩

២៩-១២-២០០៥ -អនុក្រឹត្យលេខ ១៤៧ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៧៨១៥

២៩-១២-២០០៥ -អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ៧៨៣៥

៣០-១២-២០០៥ -អនុក្រឹត្យលេខ ១៤៩ អនក្រ.បក ស្ដីពីការកែសម្រួលមាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ៧៨៥៤

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩០៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៥៨

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩០៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៨៥៩

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១០ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៨៦០

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១១ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៦៧

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១២ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៧៨៦៩

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៧០

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៨៧១

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧២

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៦ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៧៣

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៧ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៨៧៤

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៧៥

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩១៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧៦

២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២០ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧៨
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២១ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧៩
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២២ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៨១
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៣ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៨២
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៤ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៨៤
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៥ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៨៦
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៦ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៨៧
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៧ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៨៨
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៨ អនក្រ.បក ស្តីពីការជូនមេដាយការងារ ៧៨៨៩
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩២៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៩២
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩៣០ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៩៤
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩៣១ អនក្រ.បក ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ៧៨៩៥
២៦-១២-២០០៥ -អនុក្រឹត្យលេខ ៩៣២ អនក្រ.បក ស្តីពីការកែសំរួលឋានន្តរសក្តិ នាយនគរបាលជាតិ ៧៨៩៦
២៧-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៣ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ៧៨៩៧
២៧-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៤ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៨៩៨
២៨-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៥ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៨៩៩
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៦ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០០
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៧ អនក្រ.បក ស្តីពីការជូនមេដាយការងារ ៧៩០២
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៨ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៣
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៣៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៤
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៤០ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៥
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៤១ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៦
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៤២ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៨
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៤៣ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩០៩
៣០-១២-២០០៥ -អនុក្រឹត្យលេខ ៩៤៤ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៩១០

## III~ការិយាល័យក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៩-១២-២០០៥ -ប្រកាសអន្តរក្រសួងលេខ ៩៨១ សហវ ស្តីពីគោលការណ៍ចំណាយសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (PAP) នៅក្រសួងអប់រំ យុវជន និង កីឡា ៧៩១១


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល


២៦-១២-២០០៥ -ប្រកាសលេខ ១000 ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សំ សុង (ខេមបូឌា) ខូ អិលធីឌី បង្កើតរោង ចក្រ "កាត់ដេរសម្លៀកបំពាក់ និងបោះពុម្ព" ដែលមានឈ្មោះថា "សំ សុង (ខេមបូឌា)ខូ អិលធីឌី" ៧៩១៧

២៦-១២-២០០៥ -ប្រកាសលេខ ១00១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី អេស ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អ៊ី អេស ហ្គាមេន" ៧៩១៩

២៦-១២-២០០៥ -ប្រកាសលេខ ១00២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គូលដេន ប្រូហ្វិត (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហ្គូលដេន ប្រូហ្វិត (ខេមបូឌា) ហ្គាមេន" ៧៩២១

២៧-១២-២០០៥ -ប្រកាសលេខ ១០១៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេសប៊ីអិម-ស៊ីជី បង្កើតរោងចក្រ "ផលិតម្សៅជំឡូងមី" ដែលមានឈ្មោះថា "អេសប៊ីអិម-ស៊ីជី" ៧៩២៣


### ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួង កិច្ចការនារី


២៩-១២-២០០៥ -ប្រកាសលេខ ១១ កកន/ប្រក ស្តីពីការបង្កើតការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទក្រសួងកិច្ចការនារី ៧៩២៥


### ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម


០៧-១២-២០០៥ -លិខិតលេខ ២៧៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស.ធី.អូ ឡៀល អ៊ីស្តេត អេន ខនស្ត្រាក់សិន** ៧៩២៨

០៧-១២-២០០៥ -លិខិតលេខ ២៧៣៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឃែតីថល ហ្វាម៉ាស៊ី សេនធ័រ** ៧៩៣០

០៧-១២-២០០៥ -លិខិតលេខ ២៧៣៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **តាឡា សាយអិនស៍ ថេកណូឡូជី គ្រុប** ៧៩៣២

០៧-១២-២០០៥ -លិខិតលេខ ២៧៣៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជីងផាន ធានហ្វ៉ំរ** ៧៩៣៤

០៧-១២-២០០៥ -លិខិតលេខ ២៧៣៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យ៉ាគីន ប៊ីលីហ្វ អ៊ិនទេសមេន** ៧៩៣៦

០៩-១២-២០០៥ -លិខិតលេខ ២៧៤០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដាប់ប៊ែលយូ អិល អេច ស៊ី (ខេមបូឌា) លីមីធីត** ៧៩៣៨

០៩-១២-២០០៥ -លិខិតលេខ ២៧៤២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិនហ្វីនីធី សីបផ្លាយ** ៧៩៤០

០៩-១២-២០០៥ -លិខិតលេខ ២៧៤៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**រ៉ូយ៉ាល់ ផ្លាស់ ខូ អិលធីឌី** ៧៩៤២

១៣-១២-២០០៥ -លិខិតលេខ ២៧៥៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សហគមន៍ អតិថវណ្ណន៍ ជាតិ** ៧៩៤៤

១៣-១២-២០០៥ -លិខិតលេខ ២៧៥៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ភូត លែន ខប** ៧៩៤៦

១៤-១២-២០០៥ -លិខិតលេខ ២៧៦៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្រីសស្តែនសេន (ខេមបូឌា) ស៊ីបយ៉ាដ លីមីធីត** ៧៩៤៨

១៤-១២-២០០៥ -លិខិតលេខ ២៧៦៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថាត់ ហៃ តេឡេខម ខូ អិលធីឌី** ៧៩៥០

១៤-១២-២០០៥ -លិខិតលេខ ២៧៧១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អរុណ ទិកចឺរ** ៧៩៥២

១៥-១២-២០០៥ -លិខិតលេខ ២៧៧៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីធី ខ្លេសស៊ីហ្វាយ** ៧៩៥៤

១៥-១២-២០០៥ -លិខិតលេខ ២៧៧៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ូ ជិន អ៊ិនជាសស្ទ្រី & ឌីវេឡុបមេន** ៧៩៥៦

១៥-១២-២០០៥ -លិខិតលេខ ២៧៧៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជីម លី (ខេមបូឌា) តីធីអ៊ី** ៧៩៥៨

១៦-១២-២០០៥ -លិខិតលេខ ២៧៨៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**ប៉េជីង តុង អេន តាំង (ថៃ ម៊ុន ហ៊ុង)** ៧៩៥៩

១៦-១២-២០០៥ -លិខិតលេខ ២៧៩៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**គ្លូប៊ល ស៊ីស្ទឹម** ៧៩៦១

១៩-១២-២០០៥ -លិខិតលេខ ២៧៩៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**ខូខេម ជេវីស៊ី ខូ អិលធីឌី** ៧៩៦៣

១៩-១២-២០០៥ -លិខិតលេខ ២៨០៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**ញ្ញាណ នារី** ៧៩៦៥

១៩-១២-២០០៥ -លិខិតលេខ ២៨០៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**យូនីវើសល អ៊ិនវេសមេន លីមីធីត** ៧៩៦៧

២១-១២-២០០៥ -លិខិតលេខ ២៨០៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**តូច ហ៊ាង អ៊ិនខបភើរេសិន** ៧៩៦៩

២១-១២-២០០៥ -លិខិតលេខ ២៨១៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**ប៊ី ឌី អិម អេស អ៊ិនធើណេសិនណល មេឌីខល សឺវីស ខមភេនី លីមីធីត** ៧៩៧១

២១-១២-២០០៥ -លិខិតលេខ ២៨២០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន

**អេស អ ប្រូឌីធី អ៊ិនវេសមេន ខមភេនី លីមីធីត** ៧៩៧៣

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក វ៉ាង ឈីងហ្វា "WANG QINGHUA" ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩២៩ នៅក្រុងហ្គងតុង ប្រទេសចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៩១២.៥៣៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០៥/៤៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

តែងតាំង

លោក តុង សេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥១២.៥៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៧៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង ឥន

នស/រកត/១២០៥/៥០៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ជូនមេបញ្ជាការ និងមេបញ្ជាការរង របស់យោធភូមិភាគទី ៧ និងទី ៩ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន ០៣រូប ដូចខាងក្រោមនេះ :

១- ឯកឧត្តម ឧត្តមសេនីយ៍ទោ HUYNH TIEN PHONG
២- ឯកឧត្តម ឧត្តមសេនីយ៍ទោ LUU PHUOC LUONG
៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ LE MANH

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥១២.៥៤១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៥*

លេខ : ៤៧៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានបញ្ឈប់តំណែងឯកឧត្តម សំ សុខ ជាទីប្រឹក្សាសម្តេច នរោត្តម សិរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី ។

មាត្រា ២: ត្រូវបានតែងតាំងឯកឧត្តម ស៊ីន ម៉េងស្រ៊ុន ជាទីប្រឹក្សាសម្តេច នរោត្តម សិរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួស ឯកឧត្តម សំ សុខ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥១២.៥៤២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៥*

លេខ ៤៨០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាំ ទី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលការប្រោសព្រះរាជទាននូវ **គ្រឿងឥស្សរិយយស** តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីជាន់ខ្ពស់ នាយទាហាន នាយនគរបាល និង សប្បុរសជន ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | | |
|---|---|---|
| ១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | យូ ស៊ុនឡុង |
| ២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ប្រាក់ ចណ្ណឌី |
| ៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ហ៊ុយ ពិសិដ្ឋ |
| ៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ហ៊ីង ប៊ុនហៀង |
| ៥- | ឯកឧត្តម | ស៊ូ គីរិន្ទ |
| ៦- | ឯកឧត្តម | ស្មោង សារ៉ាត់ |
| ៧- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | ចៅ តុល |
| ៨- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | ឡៅ សារុន |
| ៩- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | យុន ចុច |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | ពិន ណារិទ្ធ |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ត្រី | ហេង ពៅ |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក ផាន់ ខួន
២- ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ូ គឹមស៊ួន
៣- ឯកឧត្តម ហ៊ុន ស៊ីថា
៤- ឯកឧត្តម ជា ចំរើន
៥- ឯកឧត្តម សួស យ៉ារ៉ា
៦- ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ យាន
៧- ឯកឧត្តម ឧត្តមសេនីយ៍ត្រី អ៊ុច សារិទ្ធ
៨- ឯកឧត្តម ឧត្តមសេនីយ៍ត្រី គង់ ចណ្ណា
៩- លោក ឧត្តមសេនីយ៍ត្រី ណុប រតនា
១០- លោក ឧត្តមសេនីយ៍ត្រី សោម ដន
១១- លោក ឧត្តមសេនីយ៍ត្រី ប៊ុច សូធី
១២- លោក ឧត្តមសេនីយ៍ត្រី នួន ណារិទ្ធ
១៣- លោក ឧត្តមសេនីយ៍ត្រី នោត ចន្ថា
១៤- លោក ឧត្តមសេនីយ៍ត្រី យង់ សារិទ្ធ
១៥- លោក ឧត្តមសេនីយ៍ត្រី ស៊ឹម សុទ្ធ
១៦- លោក ឧត្តមសេនីយ៍ត្រី សុខ ភាព
១៧- លោក អ៊ុយ សារិន
១៨- លោក ឌិត ដា
១៩- លោក វរសេនីយ៍ឯក អ៊ុត សុទ្ធសេន
២០- លោក វរសេនីយ៍ឯក ជា លីស្រ៊ួន
២១- លោក វរសេនីយ៍ឯក លន់ សុធី

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រល.០៥១២.៥៤៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥*

លេខ : ៤៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥០៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម លី សំអាន ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកទូរគមនាគមន៍អន្តរជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧ល.០៥១៧.៥៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ៤៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាអ៊ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស, កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

**ចំពោះ**

- លោកជំទាវ **ម៉ែន គន្ធី ហុក ឡុងឌី**

**នូវ**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ាល.០៥១២.៥៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ ៤៨១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

៤៦

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

**ចំពោះ**

- ឯកឧត្តម ចៅ គិរុណា

**នូវ**

គ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៥១២.៥៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ ៤៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ អាន

3/3

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៤រូប ដូចខាងក្រោមនេះ :

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :
ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ឹង សំផន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :
១- ឯកឧត្តម ឡេង អំ
២- ឯកឧត្តម សួស អុក្ខារ៍

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :
លោកជំទាវ លាង ខួចឆេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៖ល.០៥១៧.៥៥១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១០០ /០១០ / ២០០៥

ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ :០៧៣/០០៥ /២០០៥ កបធ.ច

ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០០៥ របស់លោក **ឆន ស្រេង** ជាអនុប្រធានក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ខេត្តព្រៃវែង ផ្ទេរសិទ្ធិឱ្យលោកមេធាវី **ម៉ៅ សុភារិទ្ធ** សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារ និង ធ្វើជាតំណាង

- បានឃើញពាក្យបណ្តឹងរបស់លោក ម៉ៅ សុភារិទ្ធ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៥ដែលប្តឹងជំទាស់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៥ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៥ វេលាម៉ោង ១១ ព្រឹក
- បានឃើញលិខិតបង្គាប់ការលេខ ៤២៥/០៥ គ.ជ.ប ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៥ របស់ឯកឧត្តម អ៊ឹម សូស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបំភ្លឺក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងលោក ម៉ៅ សុភារិទ្ធ តំណាងឱ្យគណបក្ស សម រង្ស៊ី មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ឈ្មោះ ខឹម វាសនា ត្រូវបានគណបក្សសម រង្ស៊ីលុបឈ្មោះចេញពីបញ្ជីសមាជិកគណបក្សតាមសេចក្តីសម្រេចលេខ ០៥០ សសរ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៥ ។ ដូច្នេះឈ្មោះ ខឹម វាសនា ប្រាសចាកពីសមាជិកភាពគណបក្សជាប់ឆ្នោត (គណបក្ស សម រង្ស៊ី) តាមបទបញ្ញត្តិនៃប្រការ ៨៣ ថ្មីនៃបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា និង ត្រូវបាត់បង់គុណភាពជាតំណាងរាស្ត្រ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៥ ដែលតម្កល់សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង ដែលសំអាងថា ឈ្មោះ ខឹម វាសនា នៅជាតំណាងរាស្ត្រ ដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចុះឈ្មោះក្នុងបញ្ជីអ្នកចុះឈ្មោះបោះឆ្នោត ពុំមានមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ឡើយ ។

## ហេតុដូច្នេះ

## សម្រេចចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក ម៉ៅ សុភារិទ្ធ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៥ ។

**មាត្រា ៣.-** ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លុបឈ្មោះ **ខឹម វាសនា** ចេញពីបញ្ជីចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី២ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃ អាទិត្យ ទី ២២ ខែ មករា ឆ្នាំ២០០៦ ។

**មាត្រា ៤.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជំនុំជម្រះជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៥ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ១៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លី ដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័ន សម្រាប់ការផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

**មាត្រា ២ .-**

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ÷

- សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម
- ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់
    - ការដាំដំណាំស្បៀង ឬ ដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចំការឈើ
    - ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
    - ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃ

វត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ឬ

• សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តសិទ្ធិនោះតាមការផ្តល់សិទ្ធិប្រទានពីនាយករដ្ឋមន្ត្រី និងបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ
- ស្ថាប័នដាក់បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់ឱ្យអនុវត្តនូវវិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងលើសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច។

**មាត្រា ៣ ..**

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឱ្យ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម ÷

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ដែលតម្រូវឱ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប
- សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ
- បង្កើតភាពមានការងារធ្វើនៅជនបទ ក្នុងក្របខ័ណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប
- លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង
- បង្កើតចំណូលរដ្ឋ ឬចំណូលខេត្តក្រុង ឃុំសង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ ។

## ជំពូកទី ២

## លក្ខខណ្ឌទូទៅសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៤ ..**

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឱ្យចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង ៥ ដូចខាងក្រោម ÷

១. ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

២. ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ ។

៣. ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន ។

៤. ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន ។

៥. ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់ ។

**មាត្រា ៥ ៈ**

ការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម ÷

- ការបង្កើនផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប
- ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន
- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- ការចៀសវាង ឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់អវិជ្ជមានសង្គម
- ការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការកែច្នៃវត្ថុធាតុដើម ជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន ។

## ជំពូកទី ៣
## នីតិវិធីសម្រាប់ផ្តួចផ្តើម ការស្នើសុំ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៦ ៈ**

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ច មានពីររូបភាពគឺ ÷

១. សំណើមានការអំពាវនាវ ដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោង ដើម្បីអំពាវនាវឱ្យអ្នកវិនិយោគដាក់សំណើ ។

២. សំណើមិនមានការអំពាវនាវ ដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋ ដើម្បីសុំការអនុញ្ញាត ។

### ផ្នែកទី ១
### ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវឱ្យដាក់សំណើ

**មាត្រា ៧ ៈ**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកផ្តួចផ្តើមលើកគម្រោងសម្បទានដីសេដ្ឋកិច្ច តាមជំហានដូចតទៅ÷

១. រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច តាមទម្រង់ដែលត្រូវបង្កើតឡើងដោយ

លេខាធិការដ្ឋានបច្ចេកទេស ហើយដែលត្រូវមានបញ្ចូលព័ត៌មានដូចចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ ។

២. បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេស ដើម្បីធ្វើការពិនិត្យសិក្សា និងផ្តល់អនុសាសន៍បឋម ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

៣. ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច ។

៤. រៀបចំឱ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

៥. ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ ត្រូវរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ។

៦. រៀបចំឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើ ជាមូលដ្ឋានក្នុងការរៀបចំឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ដែលមានការអំពាវនាវ ។

**មាត្រា ៨ .-**

ឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច ត្រូវមានបញ្ចូលព័ត៌មានដូចខាងក្រោម ៖

១. ការពណ៌នាអំពីដីដែលស្នើឡើង ដូចជាទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី និងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះស្ថិតនៅ ។

២. ផែនការទូទៅអំពីការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន ។

៣. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យសម្បទានិកធ្វើ មុនពេលចាប់ផ្តើមសកម្មភាពលើសម្បទានដីសេដ្ឋកិច្ចនោះ ប្រសិនបើមាន ។

៤. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ឬក្រសួង ស្ថាប័នណាមួយធ្វើមុនពេលចាប់ផ្តើមអនុវត្តសកម្មភាពសម្បទានដីសេដ្ឋកិច្ច ប្រសិនបើមាន ។

៥. ការធានារបស់រដ្ឋ ឬកាតព្វកិច្ចរបស់រដ្ឋ ប្រសិនបើតម្រូវឱ្យមានសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៩ .-**

នៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំឯកសារ ដោយមានការអំពាវនាវឱ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ច រួមមាន ៖

- សេចក្តីជូនដំណឹង
- ឯកសារ ស្តីពីលក្ខខណ្ឌ និង
- ពាក្យស្នើសុំ ។

**មាត្រា ១០ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវសេចក្តីជូនដំណឹងឱ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនេះ ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

សេចក្ដីជូនដំណឹងត្រូវបញ្ជាក់ពីរបៀប ទីកន្លែង និងរយៈពេលសម្រាប់ការដាក់សំណើ ដោយកំណត់នូវកាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យ។ ការដាក់សំណើត្រូវមានរយៈពេលយ៉ាងតិច ៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ។

**មាត្រា ១១ .-**

ឯកសារ ស្ដីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ ត្រូវបញ្ចូលខ្លឹមសារដូចខាងក្រោម ÷

- សេចក្ដីពណ៌នា អំពីគម្រោងសម្បទានដីសេដ្ឋកិច្ច និងឯកសារគាំទ្រដែលតម្រូវឱ្យដាក់ភ្ជាប់ជាមួយសំណើ
- លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសំណើ និង
- លក្ខខណ្ឌចាំបាច់មួយចំនួនដែលមិនអនុញ្ញាតឱ្យចរចា។

**មាត្រា ១២ .-**

ពាក្យស្នើសុំសម្រាប់សំណើមានការអំពាវនាវ ត្រូវមានភ្ជាប់ព័ត៌មានទាំងឡាយដូចខាងក្រោម ÷

- ផែនការអាជីវកម្មដែលលំអិតអំពីផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូលចំណាយសម្រាប់ការអភិវឌ្ឍដី និងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទាន
- ការពណ៌នា អំពីសេចក្ដីត្រូវការកម្លាំងពលកម្ម និងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទាន
- ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាព ដែលគ្រោងនឹងប្រើប្រាស់
- ការបង្ហាញ ពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ទៅនឹងការកែច្នៃវត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន
- ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើជូនរដ្ឋ
- ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទានសេដ្ឋកិច្ចដោយម្ចាស់សំណើ ប្រសិនបើមាន ស្របតាមការចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល និង
- កិច្ចធានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន។

**មាត្រា ១៣ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារអំពាវនាវឱ្យដាក់សំណើ យ៉ាងតិច ៣០ (សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើ និងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានធ្វើឡើង ។

**មាត្រា ១៤ .-**

លក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃ និងចាត់ថ្នាក់សំណើមានការអំពាវនាវ ត្រូវបញ្ចូលចំណុចដូចខាងក្រោម÷

- កម្រិតបច្ចេកទេសនៃការប្រើប្រាស់ និងការអភិវឌ្ឍដី រួមទាំងភាពសមស្របរបស់ដី
- ការគោរពតាមស្តង់ដារបរិស្ថានជាតិ និងវិធានការសមស្របសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម
- លទ្ធភាពដំណើរការប្រតិបត្តិការនៃសំណើ ដោយផ្អែកជាអាទិ៍លើផែនការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម ប្រភពហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រទីផ្សារនៃផែនការអាជីវកម្ម
- លទ្ធភាពបង្កើតការងារធ្វើ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការកែច្នៃវត្ថុធាតុដើម ឬកសិផលក្នុងស្រុក ដែលត្រូវកំណត់ក្នុងកិច្ចសន្យា
- លទ្ធភាពផ្សារភ្ជាប់ និងគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច
- ចំនួនទឹកប្រាក់ និងរបៀបបង់ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើឡើង ។

លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងការចាត់ថ្នាក់សំណើ មិនអាចធ្វើការកែប្រែបានឡើយ ក្រោយពីចុះផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើដែលមានការអំពាវនាវ អនុលោមតាមមាត្រា ១០ នៃអនុក្រឹត្យនេះ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំ និងផ្សព្វផ្សាយអំពីការដាក់ពិន្ទុសម្រាប់ការចាត់ថ្នាក់សំណើនីមួយៗតាមលំដាប់ ដោយផ្អែកលើលក្ខណវិនិច្ឆ័យខាងលើ ។

**មាត្រា ១៥ .-**

សំណើត្រូវដាក់ទៅលេខាធិការដ្ឋានបច្ចេកទេស ក្នុងស្រោមសំបុត្របិទជិត និងមានចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិទមុខសំបុត្រ ។

សំណើដែលបានទទួលក្រោយកាលបរិច្ឆេទបិទការទទួលសំណើ ត្រូវបង្វិលឱ្យម្ចាស់សំណើវិញ ដោយមិនត្រូវបើកស្រោមសំបុត្រឡើយ ។

សំណើទាំងអស់ ឬសំណើតែមួយ(០១)ដែលបានទទួល ត្រូវបើកជាសាធារណៈ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងសេចក្តីអញ្ជើញឱ្យដាក់សំណើមានការអំពាវនាវ ។ ម្ចាស់សំណើម្នាក់ៗមានសិទ្ធិចូលរួមមើលការបើកសំណើ ។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវកំណត់សំណើណាដែលមានលក្ខណៈឆ្លើយតប ហើយពិនិត្យ និងលើកអនុសាសន៍លើសំណើនោះ ជូនទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដែលចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ និងតាមនីតិវិធីដែលមានក្នុងឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ។

**មាត្រា ១៦ .-**

បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែលមានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្តល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់សំណើនីមួយៗ ។

**មាត្រា ១៧ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវបានអនុញ្ញាតឱ្យធ្វើការចរចាលើលក្ខខណ្ឌចាំបាច់មួយចំនួន ដែលបានកំណត់ជាមុនថាមិនអនុញ្ញាតឱ្យចរចា នៅក្នុងឯកសារអំពាវនាវឱ្យដាក់សំណើនោះឡើយ ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេ មកធ្វើការចរចាកិច្ចសន្យាសម្បទាន។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចបានកិច្ចសន្យាសម្បទាន ដោយមកពីអាជ្ញាធរមិនអាចទទួលយកលក្ខខណ្ឌដែលស្នើឡើងចុងក្រោយដោយម្ចាស់សំណើ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ឈប់ការចរចាជាមួយម្ចាស់សំណើ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់ មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់ ។

ប្រសិនបើការចរចាឈានដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទាន អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវឱ្យម្ចាស់សំណើបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

ក្នុងករណីដែលមានសំណើតែមួយ(០១) ឬពីរ(០២) លេខាធិការដ្ឋានបច្ចេកទេសក៏ត្រូវតែអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងមាត្រាខាងលើដែរ ។

## ផ្នែកទី ២
## ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើមិនមានការអំពាវនាវ

**មាត្រា ១៨ .-**

វិធីសាស្ត្រអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺវិធីសាស្ត្រអំពាវនាវឱ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចធ្វើការពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានជាអាទិ៍ ÷

- ការនាំមកនូវបច្ចេកវិទ្យាថ្មី
- ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ច ទៅនឹងសម្បទានដីសង្គមកិច្ច
- លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវទទួលយកមកពិចារណានូវសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេ ប្រសិនបើសំណើនោះទាក់ទងទៅនឹងដី ដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ដែលបានផ្សព្វផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើរួចហើយ។

**មាត្រា ១៩ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវ ដោយបញ្ចូល

សេចក្តីពណ៌នាសង្ខេប អំពីសាវតាផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិត ស្តីពីការវិនិយោគដែលស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដី និងទីតាំងដី ។

ម្ចាស់សំណើ អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ឬនៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ។ ប្រសិនបើពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគខេត្តក្រុង ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងរយៈពេល ០៧ ( ប្រាំពីរ ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យសុំ ។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សម្រេចធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះត្រង់ចំណុចទី ៣ ។ បន្ទាប់មកអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសដីធ្វើសម្បទាន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ហើយស្នើឱ្យម្ចាស់សំណើផ្តល់ជូននូវឯកសារលំអិតនៃសំណើ ។

## មាត្រា ២០ .-

ឯកសារលំអិតនៃសំណើមិនមានការអំពាវនាវត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម ÷

- ព័ត៌មានដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ និង
- របាយការណ៍នៃការសិក្សាវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ ប្រសិនបើការសិក្សាវាយតម្លៃដំបូងបង្ហាញថា អាចមានហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ សំណើនោះត្រូវបញ្ចូលរបាយការណ៍នៃការវាយតម្លៃពេញលេញអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

## មាត្រា ២១ .-

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដែលបានទទួលសំណើមិនមានការអំពាវនាវ ត្រូវអនុវត្តតាមបែបបទដូចតទៅ ÷

ក. អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវបញ្ជូនឯកសារលំអិតនៃសំណើមិនមានការអំពាវនាវទៅលេខាធិការដ្ឋានបច្ចេកទេស ឬទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ ។

ខ. លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ត្រូវផ្តល់អនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ថាគួរ ឬមិនគួរធ្វើការចរចាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ ដល់មាត្រា ៥ នៃអនុក្រឹត្យនេះ ។

## មាត្រា ២២ .-

ការចរចាចុះកិច្ចសន្យាសម្រាប់គម្រោងសម្បទានមិនមានការអំពាវនាវ ត្រូវធ្វើក្នុងរយៈពេលយ៉ាងច្រើន ២៨

(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃផ្ដើមការចរចា។ បើការចរចាមិនឈានដល់ការសម្រេចសេចក្ដីព្រាងកិច្ចសន្យាសម្បទានក្នុងរយៈពេលកំណត់នេះទេ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។

**មាត្រា ២៣ .-**

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៤ .-**

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំទម្រង់ស្តង់ដារនៃកិច្ចសន្យាសម្បទាន ដែលត្រូវប្រើសម្រាប់រាល់សម្បទានដីសេដ្ឋកិច្ច ដោយត្រូវពិគ្រោះយោបល់ និងកំណត់ប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី ៤
## ការគ្រប់គ្រង និងការកែប្រែកិច្ចសន្យាសម្បទាន

**មាត្រា ២៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តកិច្ចសន្យាសម្បទានដោយបង្កើតយន្តការ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទាន និងរាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយផ្ដល់ព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាសម្បទានរបស់សម្បទានិក និងទទួលព័ត៌មានពីសម្បទានិក និងពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការអនុវត្តកិច្ចសន្យាសម្បទាន។

**មាត្រា ២៦ .-**

មុននឹងធ្វើការកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យា ដោយអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន។

**មាត្រា ២៧ .-**

ការពន្យារ ការព្យួរ ការបញ្ចប់កិច្ចសន្យាសម្បទាន ត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាន។

## ជំពូកទី ៥
## យន្តការរដ្ឋបាល និងការអនុវត្តកិច្ចសន្យាសម្បទាន

**មាត្រា ២៨ .-**

យន្តការសម្បទានដីសេដ្ឋកិច្ច មានដូចខាងក្រោម ÷

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

- លេខាធិការដ្ឋានបច្ចេកទេស
- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ
- ក្រុមប្រឹក្សាឃុំសង្កាត់ ។

**មាត្រា ២៩ .-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគចាប់ពី ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀលឡើង ឬមានទំហំដីសម្បទានចាប់ពី ១.០០០ (មួយពាន់) ហិកតាឡើង ។

អភិបាលខេត្ត ក្រុងមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគក្រោម ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល និងមានទំហំដីសម្បទានក្រោម ១.០០០ (មួយពាន់) ហិកតា ។

**មាត្រា ៣០ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ផ្តួចផ្តើម និងរៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ចសម្រាប់អំពាវនាវឱ្យមានការដាក់សំណើ ឬអាចពិចារណាសំណើគម្រោងសម្បទានដីសេដ្ឋកិច្ច ដែលមិនមានការអំពាវនាវ
- វាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើ
- ចរចាលក្ខខណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ដាក់ឱ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- រាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជូនគណៈរដ្ឋមន្ត្រីជារៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង និងតាមការចាំបាច់
- សម្របសម្រួល ប្រមូលព័ត៌មាន និងទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ចំពោះ ដីក្នុងតំបន់អភិវឌ្ឍន៍យោធា លើលក្ខខណ្ឌដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាសម្បទាន
- ពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយ និង -
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣១ .-**

សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស មានដូចខាងក្រោម ៖

-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន

-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

-តំណាងក្រសួងមហាផ្ទៃ សមាជិក

-តំណាងក្រសួងបរិស្ថាន សមាជិក

-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

-សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

ប្រធាន និងសមាជិកនៃលេខាធិការដ្ឋានបច្ចេកទេស ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មន្ត្រីជំនួយការរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់លេខាធិការដ្ឋានបច្ចេកទេស។

លេខាធិការដ្ឋានបច្ចេកទេស មានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ៣២ .-**

លេខាធិការដ្ឋានបច្ចេកទេស មានភារកិច្ច ÷

- រៀបចំគម្រោងសម្បទានដីសេដ្ឋកិច្ច
- រៀបចំឯកសារអំពាវនាវឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ច
- ផ្តល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ផ្តល់អនុសាសន៍អំពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់ និង
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៣ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

**មាត្រា ៣៤ .-**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៨ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

**មាត្រា ៣៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋមូលដ្ឋាន ក្រោយពីទទួលបានឯកសារលំអិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ឬឯកសារ

លំអិតនៃសំណើមិនមានការអំពាវនាវ ដោយបញ្ជូនឯកសារនោះមួយច្បាប់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ដែលដីសម្បទានតាំងនៅ ដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន ២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំសង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំសង្កាត់ពាក់ព័ន្ធ។ ក្នុងករណីបដិសេធយោបល់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវផ្តល់ហេតុផលច្បាស់លាស់។

## ជំពូកទី ៦

## ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់

### មាត្រា ៣៦ .-

ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យមុនអនុក្រឹត្យនេះចូលជាធរមាន ហើយដែលកិច្ចសន្យាសម្បទាននោះនៅមានសុពលភាព ÷

- លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃបន្ទាប់ពីមានសេចក្តីសម្រេចតែងតាំង និងត្រូវជូនដំណឹងក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ។
- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬសម្បទានិកទាំងអស់ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចម្លងដែលពាក់ព័ន្ធ ដល់លេខាធិការដ្ឋានបច្ចេកទេសក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ឬការផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីចុះក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច។

### មាត្រា ៣៧ .-

ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដែលមានស្រាប់ ត្រូវអនុវត្តនូវជំហានត្រួតពិនិត្យឡើងវិញ តាមស្ថានភាពនៃករណីនីមួយៗ ដូចខាងក្រោម ÷

- ការអនុវត្តរបស់សម្បទានិក ផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន ដោយពិចារណាលើកំរិតនៃការវិនិយោគដែលបានធ្វើរួចហើយ និងដែលគ្រោងធ្វើបន្ត
- ប្រាក់ចំណូល និងថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន
- ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ច នៅឃុំសង្កាត់ ដែលដីសម្បទាននោះស្ថិតនៅ
- ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋវិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ

- ស្នើឱ្យមានការធ្វើនិយ័តកម្មដីនោះ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យនេះ
- យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស លើសេចក្ដីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ
- ក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ស្ដីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដោយមានភ្ជាប់យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀត របាយការណ៍នេះត្រូវធ្វើឡើងទៀងទាត់រៀងរាល់ ០៦ (ប្រាំមួយ)ខែម្ដង
- នៅក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា និងមិនត្រូវលុបចោល ឬមានបញ្ហាឱ្យផ្អាកដំណើរការ ហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច លើកលែងតែមានសេចក្ដីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ ។

**មាត្រា ៣៨ .-**

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ ដោយស្ម័គ្រចិត្ត ឬដោយការចរចា ដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល ត្រូវអនុវត្តដូចតទៅ ÷

- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ស្របតាមមាត្រា ៤០ នៃអនុក្រឹត្យនេះ
- ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំដីសម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវអញ្ជើញសម្បទានិកមកចរចា អំពីផែនការប្រើប្រាស់ដីសម្បទាន ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស
- ប្រសិនបើការចរចាមិនសម្រេចបានជោគជ័យនៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្ដើមការចរចា ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវរាយការណ៍ ជូនទៅគណៈរដ្ឋមន្ត្រីតាមរយៈលេខាធិការដ្ឋានបច្ចេកទេស
- ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញឱ្យមកចរចាត្រូវបានបញ្ជូនដល់អាស័យដ្ឋាន ឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដើម្បីមានវិធានការ។

**មាត្រា ៣៩ .-**

គណៈរដ្ឋមន្ត្រី មានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ដែលមានទំហំសរុបលើសពី ១០.០០០ (មួយម៉ឺន)ហិកតា ក្នុងករណីដូចខាងក្រោម ÷

- ដីសម្បទាននោះត្រូវបានផ្ដល់ឱ្យមុនពេលដែលច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន

-ការកាត់បន្ថយដីសម្បទាននោះ នាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែលច្បាប់ភូមិបាលចូលជាធរមាន។ ការកាប់ឆ្ការដើមឈើ ឬការដុតព្រៃសំអាតដី មិនត្រូវបានចាត់ទុកជាអាជីវកម្មកំពុងដំណើរការ ឬជាការបំពេញតាមលក្ខខណ្ឌនៃការអភិវឌ្ឍដីដែលចែងក្នុងកិច្ចសន្យាឡើយ ។

**មាត្រា ៤០ .-**

យោបល់របស់លេខាធិការដ្ឋានបច្ចេកទេសលើសេចក្ដីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ លើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នីមួយៗ ដែលផ្ដល់ជូនទៅក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវមានបញ្ជាក់សេចក្ដី ដូចខាងក្រោម ÷

- កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ
- កិច្ចសន្យានោះគួរមានការកែប្រែលើចំណុចជាក់លាក់ ដោយបញ្ជាក់អំពីកិច្ចការដែលត្រូវបំពេញដោយភាគីនៃកិច្ចសន្យា ដើម្បីទទួលយកបានទាំងសង្ខាង
- គួរលុបចោលកិច្ចសន្យានោះ ដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា
- ចំពោះដីសម្បទានលើសពី ១០.០០០ ( មួយម៉ឺន)ហិកតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន ។ ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្នែកដែលមានទំនាស់ ផ្នែកដែលមិនទាន់បានកាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ ។

**មាត្រា ៤១ .-**

របាយការណ៍ត្រួតពិនិត្យ អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយនៃការត្រួតពិនិត្យឡើងវិញលើសម្បទាននីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈ នៅលេខាធិការដ្ឋានបច្ចេកទេស និងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

**មាត្រា ៤២ .-**

ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើនិយ័តកម្មដីក្នុងតំបន់ដីសម្បទាន ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ។ ការធ្វើនិយ័តកម្មដីមានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។

## ជំពូកទី ៧
## ប្រភពធនធាន

**មាត្រា ៤៣ .-**

ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់លេខាធិការដ្ឋានបច្ចេកទេសបានមកពីថវិកាជាតិ និងហិរញ្ញប្បទានដែលបានមកពីប្រភពក្នុងស្រុក ឬក្រៅស្រុក ឬពីអ្នកផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្តក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៤៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុលោមតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

## ជំពូកទី ១

## ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា « ក.អ.ក » មានសមាសភាពដូចតទៅ÷

១- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល សហប្រធាន

២- សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល សហប្រធាន

| | | |
|---|---|---|
| ៣- | ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៤- | ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥- | ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធាន |
| ៦- | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ឬតំណាង | សមាជិក |
| ៨- | សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៩- | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតំណាង | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងពត៌មាន ឬតំណាង | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | សមាជិក |
| ១៤- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង | សមាជិក |
| ១៥- | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ឬតំណាង | សមាជិក |
| ១៦- | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង | សមាជិក |
| ១៧- | រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ឬតំណាង | សមាជិក |
| ១៨- | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ឬតំណាង | សមាជិក |
| ១៩- | រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង | សមាជិក |
| ២០- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង | សមាជិក |
| ២១- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ២៣- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ២២- | រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ២៤- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬតំណាង | សមាជិក |
| ២៥- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ២៦- | រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ឬតំណាង | សមាជិក |
| ២៧- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ២៨- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬតំណាង | សមាជិក |
| ២៩- | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឬតំណាង | សមាជិក |
| ៣០- | រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ឬតំណាង | សមាជិក |
| ៣១- | អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬតំណាង | សមាជិក |

៣២- រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង សមាជិ.

៣៣- រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬតំណាង សមាជិក

៣៤- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ឬតំណាង សមាជិក

៣៥- អគ្គស្នងការនគរបាលជាតិ ឬតំណាង សមាជិក

៣៦- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឬតំណាង សមាជិក

៣៧- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៣៨- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា សមាជិក

៣៩- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

៤០- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា សមាជិក

៤១- អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក

៤២- អភិបាលខេត្ត-ក្រុង ឬ តំណាង សមាជិក

៤៣- ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឬ តំណាង សមាជិក

**មាត្រា ២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ « គ.ជ.នា» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាមួយរូប ។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ « គ.វ.ក» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ « គ. ស.៣» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៤- អគ្គលេខាធិការដ្ឋាននៃ « ក.អ.ក » ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ អគ្គលេខាធិការ « ក.អ.ក » ។

**មាត្រា ៣ :** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ៈ អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និង អគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មាន អគ្គលេខាធិការរងមួយរូប១រៀង១ខ្លួនសម្រាប់ជាជំនួយការក្នុងការងារ ។ អគ្គលេខាធិការរងនីមួយ១ត្រូវបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់ឱ្យ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក » ។ អគ្គលេខាធិការមួយរូប១ ត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន ។

**មាត្រា ៤** : គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ កៀរគរ និង សម្របសម្រួលជំនួយ

២- ផ្នែកឯកសារ និង គ្រប់គ្រងពត៌មាន

៣- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងជំនួយពហុភាគី (ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ ។ល។)

៦- ផ្នែកគ្រប់គ្រងជំនួយរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និង បណ្តាអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកសម្របសម្រួល និង ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោង

៩- ផ្នែករដ្ឋបាល ។

**មាត្រា ៥** : គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ និង ការជម្រុញគម្រោងវិនិយោគឯកជន

២- ផ្នែកវិភាគគម្រោង និង ការលើកទឹកចិត្ត

៣- ផ្នែកវាយតំលៃខាងបរិស្ថាន

៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង

៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៦- ផ្នែកនីតិកម្ម និង ច្បាប់វិនិយោគ

៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ

៨- ផ្នែករដ្ឋបាល

**មាត្រា ៦** : គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកគោលនយោបាយ និងផែនការ

២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង

៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង

៤- ផ្នែករដ្ឋបាល

**មាត្រា ៧ :** អគ្គលេខាធិការដ្ឋានរួមមាន « ផ្នែកគាំទ្រ » ចំនួន ៤ ÷

១- ផ្នែកនីតិកម្ម និង ដោះស្រាយវិវាទ

២- ផ្នែកហិរញ្ញវត្ថុ និង រដ្ឋបាល

៣- ផ្នែកគ្រប់គ្រងមន្ត្រី និង បុគ្គលិក

៤- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ ។

**មាត្រា ៨ :** ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមាន អនុប្រធានមួយរូប ឬ ច្រើនរូបជាជំនួយការ ។

**មាត្រា ៩ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ។ គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ ÷

១- សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ច និង ភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១០ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ ÷

១- ជាសេនាធិការ និង ជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និង ការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

២- ដឹកនាំការងាររៀបចំទស្សនទាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ប្រទេសកម្ពុជាដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ។

៣- ទាក់ទងជាមួយប្រទេស អង្គការអន្តរជាតិពហុភាគី/ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ក្នុងគោលបំណងធ្វើអោយគេយល់ជ្រួតជ្រាបអំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃកម្មវិធី

ជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួលនិងការប្រើប្រាស់ជំនួយអន្តរជាតិអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ។

៤- សម្របសម្រួលការងាររវាងក្រសួង និង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ជាមួយនឹងប្រទេស និង អង្គការ អន្តរជាតិអ្នកផ្តល់ជំនួយ ព្រមទាំងជាមួយអ្នកវិនិយោគ ។

៥- តម្រង់ទិសក្នុងការបែងចែក និង ក្នុងការប្រើប្រាស់ធនធានសាធារណៈ និង ធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

៦- បង្កលក្ខណៈងាយស្រួល និង សម្រួលកិច្ចការដល់អ្នកផ្តល់ជំនួយ និង ដល់អ្នកវិនិយោគ ។

៧- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និង ការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

**មាត្រា ១១ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រី លើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ÷

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គំរោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា ១២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន ។

**មាត្រា ១៣ :** ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងរាជរដ្ឋាភិបាលជាមួយ នឹងប្រទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងស្ថាប័ននានា នៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួលជំនួយ និង /ឬ ការបែងចែកជំនួយ ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ ។

៣- កៀរគរ និងវិភាជន៍ជំនួយបរទេស សំរាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ ។

៤- ដឹកនាំផ្ទាល់កិច្ចការសុខដុមនីយកម្មនៃការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយបរទេស ។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលជាយន្តការសំរាប់ពិភាក្សាក៏រិតគោលនយោបាយ និងផ្តល់ការគាំទ្រនានាសំរាប់ពង្រឹងយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

៦- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំទស្សនាទានជាយុទ្ធសាស្ត្រសម្រាប់និតិសម្បទា និងអភិវឌ្ឍន៍ប្រទេសនិងដើម្បីលើកឡើងនូវលំដាប់អាទិភាពនៃតម្រូវការរបស់ប្រទេសជាតិ ក្នុងពេលបច្ចុប្បន្នជាបន្ទាន់និងសម្រាប់រយះពេលខ្លី រយះពេលមធ្យម និងរយះពេលវែង ដើម្បីបង្កើតឡើងនូវកម្មវិធីការងាររំកិលតាមឆ្នាំ។ កម្មវិធីនេះ ត្រូវមានលក្ខណះជាប្រព័ន្ធរលូនប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា។

៧- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសម្រាប់អភិវឌ្ឍន៍កម្ពុជា។

៨- គ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ ។ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតំរង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

៩- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី និង/ឬ អង្គការអន្តរជាតិនានា ដើម្បីទទួលជំនួយ និង /ឬ ការបែងចែកជំនួយ ។

១០-ដឹកនាំការងារក្នុងការរៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំអន្តរជាតិ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញដូចជា «ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា» ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ។

១១-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍ ។

**មាត្រា ១៤ :** ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក» ជាអ្នកសម្របសម្រួលក្នុងការលើកទស្សនទានជាយុទ្ធសាស្ត្រ និងគោលនយោបាយនៃកិច្ចការវិនិយោគសាធារណៈ ព្រមទាំងជាអ្នកសម្របសម្រួល ក្នុងការកំណត់ លំដាប់អាទិភាពនៃកម្មវិធី និងគម្រោង វិនិយោគសាធារណៈសម្រាប់រយះពេលមធ្យម និងរយះពេលមួយឆ្នាំ ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្គួចការទូតផ្លូវការ ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នករៀបចំផែនការ ៥ ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការប៉ាន់ស្មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកា សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ។

៥- ក្រសួងជំនាញ ជាអ្នករៀបចំកម្មវិធី និងគម្រោងការវិនិយោគសាធារណៈតាមផ្នែកដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ«ក.អ.ក» ព្រមទាំង ជាមួយអ្នកអនុវត្តកម្មវិធី និងគម្រោងការវិនិយោគសាធារណៈតាមផ្នែក ដែលមានការពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន ។

**មាត្រា ១៥** : ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារនិងបំពេញកាតព្វកិច្ចរបស់ខ្លួន ខាងវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៦** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តន៍កម្មវិធី និង/ឬ គម្រោងស្របតាមសមត្ថកិច្ចរៀងៗខ្លួនដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៧** : ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ច ដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ «ច្រកចេញចូលតែមួយ» និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និង សម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ «ការប្រណាំងប្រជែងដណ្តើមឈ្នះ» លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជា «សាជីវកម្មកម្ពុជា» ។ សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានា សម្រាប់ការវិនិយោគឯកជន ។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកវិនិយោគ តាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ញត្តិផ្ទៃក្នុង នៃ «ក.អ.ក» ។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោង សម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

៥- ល្មើកគម្រោង និងផ្តល់យោបល់ជូនរដ្ឋាភិបាល ស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតល័ក្ខខ័ណ្ឌ ដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន ។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និង ក្រៅប្រទេស ។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារវិនិយោគឯកជន ។

**មាត្រា ១៨** : ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក» បំពេញតួនាទីជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគំរោងខ្លះ មិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៩** : ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា និងក្រសួង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ២០** : ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា រួមជាមួយ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬ ស្ថាប័ន ដែលមានការពាក់ព័ន្ធ ជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជន ដែល«ក.អ.ក» បានផ្តល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ២១** : ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា មានភារកិច្ច ដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ «ច្រកចេញចូលតែមួយ» និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ

និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាព រដ្ឋ ឯកជនចម្រុះរដ្ឋ និង ឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើង នូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចអោយបាននូវទស្សនៈនេះ ដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជាតំបន់ សាជីវកម្មទំនើបនាពេលអនាគត។

៣-ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានា ដែលមាន ប្រសិទ្ធភាព និងឆាប់រហ័ស ។

៤- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល។

៥- លើកគម្រោងនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិនានា និង ដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតលក្ខខ័ណ្ឌ ដែលអនុគ្រោះ និង ដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរ នានា និង កាធ្វើអធិការកិច្ច ចំពោះតំបន់សេដ្ឋកិច្ចពិសេស ។

៧- ចាត់បញ្ជូនមន្ត្រីដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស និងតម្រង់ទិសការងារវិនិយោគតំបន់។

**មាត្រា ២២:** ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេសដែលមាន ការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក» បំពេញតួនាទីជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និង សម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើ គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ។

៣- សហការជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ច ពិសេស ប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ២៣ :** សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក»

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៣- ដឹកនាំពិភាក្សា និង ថែរក្សាសណ្តាប់ធ្នាប់ នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គ «ក.អ.ក» ។

៤- ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ។

៥- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និង ប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក » ។

៦- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ «ក.អ.ក » ។

**មាត្រា ២៤ :** នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់នូវការលើក និងការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និង នូវការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ។

**មាត្រា ២៥ :** អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

**ក.** ឯកឧត្តម គាត ឈន់ អនុប្រធានទី១ ÷

១- ទទួលខុសត្រូវរួមលើការងាររបស់«ក.អ.ក»ក្នុងករណីដែលសហប្រធាន «ក.អ.ក » អវត្តមាន។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជារួម។

៣- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលជំនួយបរទេស ។

៤- ទទួលខុសត្រូវក្នុងការដឹកនាំ និង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ «ក.អ.ក» ។

៥- ធ្វើជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ«ក.អ.ក » និង អង្គប្រជុំពេញអង្គរបស់ «ក.អ.ក » និង ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំនោះ ក្នុងករណីដែលសហប្រធាន «ក.អ.ក» អវត្តមាន ។

៦- ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង «ក.អ.ក » ជាមួយនឹងក្រសួងស្ថាប័ន នានា នៃរាជរដ្ឋាភិបាល ។

៧- ទទួលបន្ទុកក្នុងការទាក់ទងជាមួយប្រទេស និង អង្គការអន្តរជាតិអ្នកផ្តល់ជំនួយនានា។

៨- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើង ដោយ «ក.អ.ក » ដើម្បីពិនិត្យឯកភាពក្នុងយន្តការ«ច្រកចេញចូលតែមួយ» លើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា មុននឹងដាក់ស្នើសុំសេចក្តីសម្រេចពីអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ។

៩- បំពេញការងារដទៃទៀតដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**ខ.** ឯកឧត្តម ចម ប្រសិទ្ធ អនុប្រធាន÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក »ក្នុងករណីដែលសហប្រធាន និង អនុប្រធានទី ១ នៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និង ស្នើគោលនយោបាយ និង យុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន និង កិច្ចការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និង យុទ្ធសាស្ត្រនេះ។

៣- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន ។

៤- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន។

៥- ទទួលបន្ទុកពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជន ដែលមានលក្ខណៈសាមញ្ញ ដូចជារោងចក្រកាត់ដេរ-រោងចក្រស្បែកជើង-ឧស្សាហកម្មគាំទ្រ-សណ្ឋាគារជាដើម និងគំរោងដែលសម្តេចនាយករដ្ឋមន្ត្រីបានសំរេចរួចហើយ ព្រមទាំងបណ្តាគំរោង ដែលមិនទាមទារការលើកទឹកចិត្តផងដែរ ។

៦- បំពេញការងារដទៃទៀត ដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

ឥ. ឯកឧត្តម គង់ វិបុល អនុប្រធាន÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលសហប្រធាន និងអនុប្រធានទាំងពីររូបនៃ «ក.អ.ក» អវត្តមាន។

២- ទទួលបន្ទុកការងារប្រចាំរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ«ច្រកចេញចូលតែមួយ» ដែលរៀបចំដោយ«ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ក្នុងករណីឯកឧត្តម ចម ប្រសិទ្ធ អវត្តមាន ឬ ជាប់រវល់ ដោយប្រការណាមួយ ។

៤- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA)ដោយសម្របសម្រួលជាមួយអនុប្រធានពីររូបទៀត។

៥- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក»ក្នុងករណីដែលសហប្រធាន និងអនុប្រធានពីររូបទៀតនៃ«ក.អ.ក» អវត្តមាន ។

៦- បំពេញការងារដទៃទៀតដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ។

**មាត្រា ២៦ :** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ÷

១- ទទួលបន្ទុកក្នុងការសម្របសម្រួល និង តាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ព្រមទាំងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាន នៃ «ក.អ.ក»។

២- ធ្វើជាសេនាធិការបច្ចេកទេសអោយ «ក.អ.ក» ក្នុងការដឹកនាំអនុវត្ត និង តាមដានការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ ពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។

៣- រៀបចំកម្មវិធីការងាររបស់ «ក.អ.ក» និងរៀបចំរបៀបវារៈ និង សំណុំឯកសារផ្សេងៗសម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ«ក.អ.ក»អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- រៀបចំកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ដើម្បីដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខា ។

៥- រៀបចំសេចក្តីប្រកាសពត៌មានរបស់ «ក.អ.ក» ។

៦- ជួយសម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេសដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័តមុននឹងផ្ញើ ជូនរាជរដ្ឋាភិបាល ។

៧- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ការវិនិយោគនានា និងការងារតំបន់សេដ្ឋកិច្ចពិសេស ។

៨- បំពេញការងារដទៃទៀត ដែលសហប្រធាន «ក.អ.ក» ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

៩- ទទួលបន្ទុកជាអគ្គលេខាធិការនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ។

**មាត្រា ២៧ :** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ «គ.ជ.នា» ។

២- រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងសម្រាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្ដាក្រសួង និងស្ថាប័នជំនាញ ដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ដើម្បីពិនិត្យ និងចាត់វិធានការណ៍កែតម្រូវក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ស្របតាមការប្រគល់ភារកិច្ចពីប្រធាន «ក.អ.ក» ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២៨ :** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ ÷

១-គ្រប់គ្រងការងាររបស់ «គ.វ.ក»

២-រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន ។

៣-ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅ

នឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង សម្រាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤-ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្ដាក្រសួង និង ស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និង លើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ដើម្បីពិនិត្យ និង ចាត់វិធានការណ៍កែតម្រូវក្នុងករណីចាំបាច់ ។

៥-ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន « ក.អ.ក » ពិនិត្យ និង អនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦-ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និង សម្រេចលើកិច្ចការវិនិយោគឯកជន ។

៧-បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ស្របតាមការប្រគល់ភារកិច្ចពីសហប្រធាន ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២៩ :** អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ «គ.ស.ព»

២- រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ«ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងការវិវឌ្ឍន៍នៃគម្រោងតំបន់ សេដ្ឋកិច្ចពិសេសនានាដោយសហការជាមួយ បណ្ដាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុបនិងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក » ដើម្បីពិនិត្យ និងចាត់វិធានការណ៍កែតម្រូវក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក » ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូន « ក.អ.ក » ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ«ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ។

៧- បំពេញការងារដទៃទៀតដែលទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ស្របតាមការប្រគល់ភារកិច្ចពីសហប្រធាន ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ។

**មាត្រា ៣០** : សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យ ការអនុវត្តគោលនយោបាយកម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័ត របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**មាត្រា ៣១** : គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ត្រូវអញ្ជើញចូលរួមប្រជុំក្នុងពីរអាទិត្យម្តង។

**មាត្រា ៣២** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកោះប្រជុំពេញអង្គក្នុងមួយខែម្តង។

**មាត្រា ៣៣** : ក្នុងករណីចាំបាច់ សហប្រធាន «ក.អ.ក» អាចនឹងកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ឬប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក» ។

**មាត្រា ៣៤** : ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងអង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក» ។

**មាត្រា ៣៥** : ការអនុវត្តការងារនៃយន្តការ «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគនានា និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបប ជាគោលការណ៍ ដូចខាងក្រោម ÷

**ទី១**- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ÷

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូប អោយមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្និតរមួត ក្នុងការទាក់ទងជាមួយប្រធានស្ថាប័ន របស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្និតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួងនិងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ» នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ «គ.ជ.នា» ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ « គ.ជ.នា » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃស្ថាប័ន «ច្រកចេញចូលតែមួយ » ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុតាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ « គ.ជ.នា» ត្រូវរៀបចំសំណុំឯកសារ និងពតិមានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ «ក.អ.ក» ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ «ក.អ.ក» ពិនិត្យ និងសម្រេច។

**ទី២**- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការវិនិយោគកម្ពុជា។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។

- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្ថិតរមូតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃ ទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ »នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.វ.ក » ចំពោះតែកិច្ចការវិនិយោគឯកជនណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ « គ.វ.ក » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ » ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.វ.ក. » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ « គ.វ.ក. » ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីពិនិត្យ និងសម្រេច។

**ទី៣**- សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចកម្ពុជា។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្ថិតរមូតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃ ទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ »នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.ស.ព »ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ច នៃក្រសួងស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ « គ.ស.ព » មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ » ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.ស.ព » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ « គ.ស.ព » ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ «ក.អ.ក » ដើម្បីពិនិត្យ និង សម្រេច។

**ទី៤**- ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងពត៌មានផ្សេងៗពី អគ្គលេខាធិការ « គ.ជ.នា » អគ្គលេខាធិការ « គ.វ.ក. » អគ្គលេខាធិការ « គ.ស.ព » មក អគ្គលេខាធិការ «ក.អ.ក » ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ « ក.អ.ក » ដើម្បីពិនិត្យ និងសម្រេច។

**មាត្រា ៣៦** : សេចក្តីលំអិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ន «ច្រកចេញចូលតែមួយ »របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ« ក.អ.ក»។

**មាត្រា ៣៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និង មានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន ។ ការគ្រប់គ្រងចំណូល និងចំណាយថវិកា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៣៨ :** អនុក្រឹត្យលេខ ៧០ អនក្រ បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ អនុក្រឹត្យ លេខ ១១២ អនក្រ បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ពាក់ព័ន្ធទាំងអស់ និង សមាសភាពនានាដូចមានក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គាត ឈន់**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៩
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងការគ្រប់គ្រង

## តំបន់សេដ្ឋកិច្ចពិសេស

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសារពើពន្ធ និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យ ក្រុមប្រឹក្សារដ្ឋ នៃរដ្ឋកម្ពុជា លេខ ៥៧ ក្រ. ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល

- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១: គោលដៅ និង ការអនុវត្តនៃអនុក្រឹត្យ

១.១ គោលដៅ

អនុក្រឹត្យនេះ មានគោលដៅ បង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនឹងបង្កើននូវបរិយាកាសវិនិយោគ ដែលអំណោយផលដល់ការធ្វើឱ្យកាន់តែប្រសើរនូវផលិតភាពក្នុងការផលិតទំនិញការប្រជែងឈ្នះ កំណើនសេដ្ឋកិច្ចជាតិ ជម្រុញការនាំចេញ ដោះស្រាយការងារជូនប្រជាជនដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមជាមួយគ្នានេះ កំណត់អំពី នីតិវិធី និងបទប្បញ្ញត្តិទាំងឡាយទាក់ទងដល់ការបង្កើត ការគ្រប់គ្រង សម្របសម្រួលរាល់សកម្មភាពវិនិយោគ និងជម្រុញលើកទឹកចិត្តដល់ការវិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងលើកស្ទួយតំបន់សេដ្ឋកិច្ចពិសេស ដើម្បីអនុវត្តន៍នូវគោលការណ៍និងលក្ខខណ្ឌ ដែលធានាបាននូវតម្លាភាពនិងប្រតិបត្តិការរហ័ស គណនេយ្យភាពចំពោះអ្នកវិនិយោគ ការទទួលបាននូវតម្រូវការអំពីព័ត៌មាន និងភាពស៊ីចង្វាក់គ្នាទៅជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចុះកន្លងមក។

១.២ ការអនុវត្ត

អនុក្រឹត្យនេះ ត្រូវដាក់ឱ្យអនុវត្តចំពោះរាល់សកម្មភាពរបស់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចពាក់ព័ន្ធ អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ច

ពិសេសទាំងអស់ ដែលបានទទួលការអនុញ្ញាតឱ្យចុះបញ្ជីវិនិយោគ និងទទួលបាននូវការលើកទឹកចិត្តនានា និងការធានាលើការវិនិយោគ ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា ២: និយមន័យ**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទបច្ចេកទេសដូចខាងក្រោម ÷

ក្រុមប្រឹក្សា សំដៅដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបង្កើតឡើងតាមមាត្រា ៣នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា សំដៅដល់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាចំណុះឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលបានបង្កើតឡើងតាមអនុក្រឹត្យ នឹងដែលមានភារកិច្ចលើការសម្រេចឱ្យបង្កើត និងធ្វើការដឹកនាំគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចមានតំបន់ឧស្សាហកម្មទូទៅ ឬ និងតំបន់ផលិតកែច្នៃនាំចេញ ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍ ។

តំបន់ឧស្សាហកម្មទូទៅ សំដៅដល់តំបន់មួយដែលបង្កើតឡើង សម្រាប់សកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀត ដែលពាក់ព័ន្ធនឹងការផលិតទំនិញ ការកែច្នៃទំនិញសម្រាប់បម្រើសេចក្តីត្រូវការនៃទីផ្សារក្នុងស្រុក ឬនិងសម្រាប់នាំចេញ ។

តំបន់ផលិតកែច្នៃនាំចេញ សំដៅដល់តំបន់នៃសកម្មភាពឧស្សាហកម្ម និង សកម្មភាពដទៃទៀតដែលពាក់ព័ន្ធនឹងការផលិត ការកែច្នៃទំនិញសម្រាប់បម្រើតែការនាំចេញប៉ុណ្ណោះ។

ធាតុចូលផលិតកម្ម សំដៅដល់ ទំនិញ រួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្ម ដែលត្រូវបានបំប្លែងឬត្រូវបានប្រើប្រាស់

យ៉ាង ពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ មិនឱ្យហួសពីរយៈពេល ២(ពីរ)ឆ្នាំ បន្ទាប់ពីបាននាំចូល ។ និយមន័យនេះ មិនគិតបញ្ចូលផងទេ នូវសម្ភារៈ និងគ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ ក្នុងការិយាល័យ ផលិតផលគេលសិលា យានយន្ត និងគ្រឿងបន្លាស់យានយន្ត ។

ធាតុចេញផលិតកម្ម សំដៅដល់ទំនិញ ដែលបានផលិតចេញពីធាតុចូលផលិតកម្ម និងដែលត្រូវ បានបំប្លែង ។

មណ្ឌលផលិតកម្ម សំដៅដល់ មណ្ឌលប្រមូលផ្តុំរោងចក្រដែលស្ថិតនៅក្នុងតំបន់ឧស្សាហកម្ម ។

មណ្ឌលពាណិជ្ជកម្មសេរី សំដៅដល់ មណ្ឌលសម្រាប់សកម្មភាពផ្គត់ផ្គង់សេវាកម្ម ស្តុក ដាក់តាំង វេចខ្ចប់ សម្អាត ឬបម្រើយការ នូវធាតុចេញផលិតកម្ម ផលិតផល សម្ភារៈបរិក្ខារ ឬ សម្ភារៈដទៃទៀត ដែលការនាំចេញពី ឬនាំចូលមកក្នុងតំបន់ត្រូវបានលើកលែងពន្ធ លើកលែងតែការនាំចេញទៅទីកន្លែងផ្សេងទៀតនៃទឹកដីព្រះរាជាណាចក្រកម្ពុជា ដែល ការនាំចូល និងនាំចេញនោះ ត្រូវទទួលរងនូវកាតព្វកិច្ចពន្ធគយ និងអាករ ទៅតាម ច្បាប់ធរមាន ។

មណ្ឌលសេវាកម្ម សំដៅដល់ មណ្ឌលសម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម និងពាណិជ្ជកម្មដូចជា ការិយាល័យចាត់ចែង និងប្រតិបត្តិការរបស់តំបន់ឧស្សាហកម្ម ធនាគារ ប្រៃសណីយ៍ អាគារលក់ទំនិញប្រចាំថ្ងៃ និងសេវាកម្មមធ្យោបាយដឹកជញ្ជូននានាផ្សេងៗទៀត។

មណ្ឌលលំនៅដ្ឋាន សំដៅដល់ មណ្ឌលសម្រាប់ការស្នាក់អាស្រ័យរបស់ កម្មករ និយោជិត និង និយោជក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅដល់ អង្គភាពគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋ ដែលជាយន្តការ ច្រកចេញចូលតែមួយនៅនឹងកន្លែងនៃតំបន់សេដ្ឋកិច្ចពិសេស និងមានភារកិច្ចចេញនូវ លិខិតអនុញ្ញាត ការយល់ព្រម អាជ្ញាប័ណ្ណ និងបញ្ជីការ រួមទាំងការអនុម័តលើ ការលើកទឹកចិត្តនានាជំនួសមុខឱ្យសាមីក្រសួង ស្ថាប័នជំនាញ តាមការទទួលសិទ្ធិ អំណាចពេញលេញរបស់ក្រសួង និងស្ថាប័នសាមីសម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគក្នុង តំបន់ជាមួយគ្នាដោះស្រាយនូវរាល់សំណូមពរនានាពាក់ព័ន្ធនឹងសមត្ថកិច្ចគ្រប់គ្រងរបស់ រដ្ឋក្នុងដំណើរការវិនិយោគនៅក្នុងតំបន់។

សម្ភារៈបរិក្ខារផលិតកម្ម សំដៅដល់ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះមិនអាចបំប្លែងដោយខ្លួនឯង ឬ ត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២(ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល ។ គ្រឿងម៉ាស៊ីន និង ឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេ នូវឧបករណ៍ ផ្នែកព័ត៌មានវិទ្យា ឬយានយន្តដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

អ្នកអភិវឌ្ឍន៍តំបន់ សំដៅដល់ អ្នកអនុវត្តន៍គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទោះជារូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរក្តី ឬនិងបរទេសក្តី ដែលបានទទួលការអនុញ្ញាតឱ្យធ្វើការវិនិយោគទុនដើម្បីអភិវឌ្ឍន៍សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅក្នុងតំបន់និងចាត់តាំងការធ្វើអាជីវកម្ម សេវាកម្ម ផ្តល់សុវត្ថិភាពផ្នែកសន្តិសុខនានា បំរើឱ្យអ្នកវិនិយោគក្នុងតំបន់។

អ្នកវិនិយោគក្នុងតំបន់ សំដៅដល់ អ្នកអនុវត្តន៍គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរក្តី ឬនិងបរទេសក្តី ដែលបានទិញឬជួលអចលនទ្រព្យពីអ្នកអភិវឌ្ឍន៍តំបន់ ហើយធ្វើសកម្មភាពវិនិយោគ ក្នុងការងារអាជីវកម្មផលិតផលិតកម្ម សេវាកម្ម ពាណិជ្ជកម្ម នៅក្នុងតំបន់នោះ។

## ជំពូកទី ២

## នីតិវិធីនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៣: ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

៣.១ លក្ខខណ្ឌនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស÷

១- តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅតាមតំបន់សមស្រប និងប្រកបដោយយុទ្ធសាស្ត្រតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយអនុលោមតាមស្មារតីសម្រេចចិត្តរបស់យន្តការច្រកចេញ ចូលតែមួយនៃក្រុមប្រឹក្សា។

២-តំបន់សេដ្ឋកិច្ចពិសេស អាចផ្តួចផ្តើមបង្កើតឡើងដោយ រដ្ឋ ឬ ឯកជន ឬ រដ្ឋចម្រុះឯកជន។

៣-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចតទៅ÷

(ក) ត្រូវមានទំហំដីចាប់ពី ៥០(ហាសិប) ហិកតាឡើងទៅ ដោយត្រូវមានទីតាំង ព្រំប្រទល់

ភូមិសាស្ត្រច្បាស់លាស់។

(ខ) មានរបងព័ទ្ធជុំវិញតំបន់(សម្រាប់តំបន់ផលិតកែច្នៃនាំចេញ និងសម្រាប់មណ្ឌលពាណិជ្ជកម្មសេរី និងតាមគ្រប់ទីតាំងផ្ទាល់របស់អ្នកវិនិយោគ ក្នុងតំបន់នីមួយៗ)។

(គ) មានអាគារការិយាល័យចាត់ចែងការងារ ការិយាល័យរដ្ឋបាលតំបន់ មានប្រព័ន្ធផ្លូវគមនាគមន៍ទូលាយ តូច ធំ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធអគ្គិសនី បណ្ដាញប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធការពារសុវត្ថិភាពទប់ទល់នឹងអគ្គិភ័យជាយថាហេតុ។ផ្អែកទៅតាមលទ្ធភាពនិងស្ថានភាពជាក់ស្ដែង តំបន់អាចមានដីបម្រុងទុក សម្រាប់មណ្ឌលលំនៅដ្ឋានរបស់កម្មករ និយោជិត និងនិយោជក មានសួនលំហែកាយ មានគិលានដ្ឋានសាលាបណ្ដុះបណ្ដាលមុខជំនាញ ស្ថានីយប្រេងឥន្ធនៈ ភោជនីយដ្ឋាន ចំណតយានយន្តអាគារលក់ទំនិញ ឬផ្សារ។ល។

(ឃ) មានប្រព័ន្ធបង្ហូរទឹកសំអុយ ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតសំណល់រាវ មានទីតាំងទុកដាក់និងគ្រប់គ្រងសំណល់រឹងត្រឹមត្រូវ មានបរិធានការពារបរិស្ថាន និងបណ្ដាហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដទៃទៀត តាមស្ថានភាពជាក់ស្ដែងនូវតម្រូវការ។

(ង) លក្ខណៈបច្ចេកទេស បទប្បញ្ញត្តិ និងបទដ្ឋានជាមូលដ្ឋាននានា បម្រើឱ្យការសាងសង់កិច្ចការបរិស្ថាន និងកិច្ចការជំនាញផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសជាមូលដ្ឋានខាងលើនេះ ត្រូវមានការកំណត់ ណែនាំដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ចជំនាញ តាមរយៈការចេញក្រុងជាបទដ្ឋានទៅតាមច្បាប់ និងស្តង់ដាជាតិ និងអន្តរជាតិផ្អែកតាមភូមិសាស្ត្រ និងទំហំជាក់ស្ដែងនៃតំបន់នីមួយៗ។

៣.២ នីតិវិធីនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស÷

១- អ្នកអភិវឌ្ឍន៍តំបន់ទាំងឡាយ ដែលមានបំណងចង់បណ្ដាក់ទុនធ្វើការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងភូមិសាស្ត្រណាមួយ ត្រូវធ្វើសំណើសុំគោលការណ៍អភិវឌ្ឍន៍តំបន់មកគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានភារកិច្ចធ្វើការសន្និដ្ឋានលើសំណើហើយលើកយោបល់ដាក់ជូនកិច្ចប្រជុំច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ដើម្បីធ្វើការសម្រេចផ្ដល់គោលការណ៍ ឬបដិសេធគោលការណ៍សុំបង្កើតតំបន់ ។

អ្នកអភិវឌ្ឍន៍តំបន់ ត្រូវបង់ថ្លៃដាក់ពាក្យសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅពេលដាក់ពាក្យចំនួន

៧ ០០០ ០០០ រៀល(ប្រាំពីរលានរៀល)ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

២- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវឆ្លើយតបអំពីលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមានរបស់សំណើក្នុងរយៈពេលយ៉ាងយូរបំផុត ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការជូនទៅអ្នកអភិវឌ្ឍន៍តំបន់វិញ។

៣- អ្នកអភិវឌ្ឍន៍តំបន់ ដែលបានទទួលគោលការណ៍ឱ្យអភិវឌ្ឍន៍ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាអាចមានពេលចំនួន១៨០(មួយរយប៉ែតសិប)ថ្ងៃនៃថ្ងៃធ្វើការ និងអាចពន្យាបានក្នុងករណីមានមូលហេតុច្បាស់លាស់ដើម្បីធ្វើគម្រោងសិក្សាសមិទ្ធិលទ្ធភាពសេដ្ឋកិច្ចលម្អិត ដែលរួមមានការបង្ហាញនូវប្លង់មេ ស្តីពីបណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ផ្លូវគមនាគមន៍ភ្ជាប់ពីក្នុងតំបន់មកក្រៅ ប្រព័ន្ធទឹក-ភ្លើង ប្រព័ន្ធការពារបរិស្ថាន តម្លៃសេវាកម្មនានាក្នុងតំបន់ តម្លៃជួលដីជួលរោងចក្រ ទឹក ភ្លើង ទូរស័ព្ទ សន្តិសុខ និងតម្លៃប្រើប្រាស់ទីលានសាធារណៈក្នុងតំបន់របស់អ្នកវិនិយោគក្នុងតំបន់ សម្រាប់កម្មករ និយោជិត និយោជកស្នាក់នៅ និងមណ្ឌលបណ្តុះបណ្តាល។ល។ និងឯកសារពាក់ព័ន្ធនានាឬលិខិតបញ្ជាក់ផ្សេងៗទៀតដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា តម្រូវទៅតាមសំណូមពររបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ដោយតម្រូវការទាំងនោះត្រូវកំណត់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌជូនអ្នកអភិវឌ្ឍន៍តំបន់ ។

៤- ក្នុងរយៈពេលយ៉ាងយូរ ១០០ (មួយរយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអ្នកអភិវឌ្ឍន៍តំបន់ដាក់គម្រោងជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដូចមានចែងក្នុងកថាខ័ណ្ឌ ៣.២ ចំណុច ៣ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវទទួលយក ជំនួសមុខឱ្យអ្នកអភិវឌ្ឍន៍តំបន់នូវ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាពីក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចឬភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចផ្តល់ឯកសារទាំងនេះ ព្រមជាមួយគ្នានូវការចេញជូនវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដល់អ្នកអភិវឌ្ឍន៍តំបន់ តាមការកំណត់នៃកថាខ័ណ្ឌនេះ ។

៥- ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំដែនខ័ណ្ឌសីមារបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗនឹងត្រូវកំណត់ដោយអនុក្រឹត្យ ស្របពេលដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរជូនអ្នកអភិវឌ្ឍន៍តំបន់ ។

៦- អ្នកអភិវឌ្ឍន៍តំបន់ ដែលមិនបានអនុវត្តគម្រោងយ៉ាងតិច ៣០ (សាមសិប) ភាគរយនៃទុនវិនិយោគសរុប ក្នុងរយៈពេល៣៦៥ (បីរយហុកសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួល

បាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានសិទ្ធិដកហូតមកវិញនូវគោលការណ៍អភិវឌ្ឍន៍តំបន់ ការលើកទឹកចិត្តនានា ដែលបានផ្តល់ជូនតាមរយៈវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរកន្លងមក។

៣.៣- នីតិវិធីសម្រាប់ការចុះបញ្ជីរបស់អ្នកវិនិយោគក្នុងតំបន់÷

បុគ្គលជាអ្នកវិនិយោគក្នុងតំបន់ ដែលចាប់ផ្តើមធ្វើសកម្មភាព ផលិតកម្ម ឬសេវាកម្មក្នុងវិស័យដែលច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធអនុញ្ញាតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសណាមួយ ត្រូវបំពេញបែបបទតាមនីតិវិធី ដោយត្រូវរៀបចំឯកសារពាក្យស្នើសុំចុះបញ្ជីវិនិយោគ នៅការិយាល័យរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដែលមានភារកិច្ចសម្រេចលើការចុះបញ្ជីនៃសំណើវិនិយោគទាំងលើទិដ្ឋភាពច្បាប់ រដ្ឋបាល និងមុខជំនាញនៅរៀងរាល់ម៉ោងធ្វើការ ដើម្បីទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរស្របតាមនីតិវិធីនៃការចុះបញ្ជីវិនិយោគដែលកំណត់ដោយច្បាប់និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ការលើកទឹកចិត្តវិនិយោគ ដែលអ្នកវិនិយោគក្នុងតំបន់មានសិទ្ធិទទួលបាន ត្រូវសម្រេចដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាមយន្តការច្រកចេញ ចូលតែមួយ នៅនឹងកន្លែងរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

រាល់សំណើផ្សេងៗទៀតក្នុងកិច្ចដំណើការរបស់អ្នកវិនិយោគតំបន់ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសបំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងការដោះស្រាយជូនអ្នកវិនិយោគក្នុងតំបន់ ជាមួយក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលតាមមុខជំនាញ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធគ្រប់គ្រង និង ភារកិច្ច

### មាត្រា ៤: រចនាសម្ព័ន្ធគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

៤.១ គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស:

គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស មានភារកិច្ចដោះស្រាយជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ឬដែលមានលក្ខណៈស្ថិតក្នុងសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង

ឬអន្តរស្ថាប័ន ហើយដែលហួសពីលទ្ធភាពសម្រេចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

ក្រៅពីនោះគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលភារកិច្ច ជាយន្តការទទួលពាក្យតវ៉ា និងដោះស្រាយសំណើតវ៉ានោះ ពីសំណាក់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ផងដែរ។

គណៈកម្មាធិការនេះ មានទីតាំងនៅទីស្នាក់ការក្រុមប្រឹក្សា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាក្នុងកិច្ចការងាររបស់ខ្លួន។

សមាសភាពរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានដូចតទៅ ÷

| | | |
|---|---|---|
| ១- | សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសហប្រធាន |
| ២- | រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- | រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- | រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួង សាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- | អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា | ជាលេខាធិការ |

ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចអញ្ជើញ សមាជិកណាមួយនៃក្រុមប្រឹក្សា ដើម្បីចូលរួមប្រជុំ នៅរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការនេះ។ សម័យប្រជុំរបស់គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅ តាមការកោះអញ្ជើញប្រជុំរបស់លេខាធិការរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសផ្អែកតាមការកំណត់ណែនាំរបស់សហប្រធាននៃគណៈកម្មាធិការនេះ។

៤.២ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា÷

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាច្រកចេញចូលតែមួយ ក្នុងការទទួលបន្ទុកលើការអភិវឌ្ឍន៍ ការគ្រប់គ្រង ការត្រួតពិនិត្យ នៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចពិសេស។

ភារកិច្ចរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាគឺ÷

១- ធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើរាល់ការងារពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្រ្ត លើកគម្រោងផែនការ និងកំណត់ទិសដៅ សម្រាប់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- កំណត់គោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធដល់ការងារតែងតាំងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ការចាត់តាំងយន្តការច្រកចេញចូលតែមួយនៅក្នុងតំបន់ ការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅនៃដំណើរការរបស់តំបន់ ការដោះស្រាយទំនាស់និងការរំលាយតំបន់ជាយថាហេតុ។

៣- អនុវត្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ ដល់អ្នកអភិវឌ្ឍន៍តំបន់ និងណែនាំគោលការណ៍នៃការលើកទឹកចិត្តរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

៤- រៀបចំគោលការណ៍ណែនាំអំពីការងារគ្រប់គ្រង និងការបណ្តុះបណ្តាលពលករ ការងារបរិស្ថាន ការងារសំណង់ ការនាំចេញ នាំចូល ការទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងកិច្ចការជំនាញផ្សេងៗ ទៀតរួមទាំងការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនង ជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យកិច្ចការរបស់តំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាព ។

៥- ធ្វើការងារអធិការកិច្ច លើរាល់សកម្មភាពមិនប្រក្រតីរបស់តំបន់ ។

៦- ដោះស្រាយរាល់សំណូមពរពាក់ព័ន្ធនឹងផលប្រយោជន៍របស់ អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ កម្មករ និយោជិត និយោជក និងបណ្តាសំណូមពរបច្ចេកទេស និងច្បាប់ផ្សេងៗ ។

៤.៣ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស÷

គឺជាយន្តការច្រកចេញចូលតែមួយ ដែលរៀបចំដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាដើម្បីប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ និងមានរចនាសម្ព័ន្ធ និងរបបការងារដូចតទៅ÷

១- សមាសភាពរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសមាន÷

- តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាប្រធាន
- តំណាងទីចាត់ការគយ និងរដ្ឋាករ សមាជិក
- តំណាងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

សមាសភាពមន្ត្រីខាងលើនេះ ត្រូវតែងតាំងដោយក្រសួង ស្ថាប័នសាមីដើម្បីឱ្យទៅប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់នីមួយៗ នៅពេលដែលតំបន់នោះចាប់ផ្តើមដំណើរការ។

២- ការិយាល័យធ្វើការរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសគឺជាបន្ទុករបស់អ្នកអភិវឌ្ឍន៍តំបន់ ក្នុងការផ្តល់ឱ្យនូវការិយាល័យធ្វើការ ដោយផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ ទឹក ភ្លើង កន្លែងសម្រាក និងការឧបត្ថម្ភនានាទៅតាមលទ្ធភាពជាក់ស្តែង ។ល។

៣- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចគ្រប់គ្រាន់ជូនតំណាងរបស់ខ្លួនក្នុងការសម្រេចការងារជួសមុខឱ្យក្រសួង និងស្ថាប័ន ស្របទៅតាមសមត្ថកិច្ចរៀងៗខ្លួននៅក្នុងតំបន់។

៤- ប្រាក់បៀវត្ស របស់មន្ត្រីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ត្រូវបើកនៅតាមអង្គភាពដើម ។

៥- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានត្រាមួយដោយឡែកសម្រាប់ប្រើប្រាស់ជាផ្លូវការលើរាល់លិខិតស្នាមទាំងអស់ បំរើឱ្យការងាររបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

ភារកិច្ចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគឺ÷

(ក) ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់ ។ អនុវត្តន៍ការត្រួតពិនិត្យបែបបទគយសម្រាប់ការចេញ ចូលទំនិញ និង សម្រួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល។

(ខ) ត្រួតពិនិត្យ ការអនុវត្តការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។

(គ) ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូនការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសម្រេចជូនអ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែង។

(ឃ) ធ្វើការត្រួតពិនិត្យការងារ សកម្មភាពតាមមុខជំនាញនៅក្នុងតំបន់ ។

(ង) សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

(ច) សម្រួលរាល់បែបបទ ដែលពាក់ព័ន្ធអោយបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។

(ឆ) ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និង ឆ្នាំ ពីសកម្មភាពរបស់តំបន់ ជូនក្រសួង ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង។

(ជ) ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសម្របសម្រួល ដោះស្រាយរាល់សំណើ របស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល។

៤.៤ អ្នកអភិវឌ្ឍន៍តំបន់ ÷

អ្នកអភិវឌ្ឍន៍តំបន់ ធ្វើសកម្មភាពស្ថិតនៅក្រោមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។ អ្នកអភិវឌ្ឍន៍តំបន់មានភារកិច្ចៈ

(ក) ត្រូវមានទុន និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ រួមទាំងធនធានមនុស្សដើម្បីដឹកនាំសកម្មភាពនៃតំបន់។

(ខ) ត្រូវមានដីធ្លី និង មានសិទ្ធិកាន់កាប់ស្របច្បាប់ ដើម្បីបង្កើតតំបន់។

(គ) ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់រួមមាន ការសាងសង់ប្រព័ន្ធអគ្គីសនី ប្រព័ន្ធទឹកស្អាត ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធថែរក្សា និងគ្រប់គ្រងបរិស្ថានរួមនៃតំបន់ សាងសង់ ឃ្លាំងផ្ទុកទំនិញ ស្ថានីយការពារអគ្គីភ័យ និងសំណង់សេវាកម្មផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់នៅក្នុងតំបន់។

(ឃ) ជួលដី ផ្តល់សេវានានា ដល់អ្នកវិនិយោគក្នុងតំបន់ កំណត់ថ្លៃឈ្នួល និងថ្លៃសេវាដែលបានផ្តល់ជូនអ្នកវិនិយោគក្នុងតំបន់ រួមមានតម្លៃ ទឹក អគ្គីសនី អាគារ ប្រព័ន្ធទូរគមនាគមន៍ អនាម័យតាមទីសាធារណៈរបស់តំបន់ កម្លាំងសន្តិសុខ និងមធ្យោបាយផ្សេងៗដែលទទួលបំរើដល់ដំណើរការប្រចាំថ្ងៃរបស់អ្នកវិនិយោគក្នុងតំបន់។

(ង) រៀបចំចាត់ចែងកងកម្លាំងសន្តិសុខយាមកាម និងធានានូវសណ្តាប់ធ្នាប់ល្អនៅក្នុងតំបន់ជាប្រចាំ ២៤ ម៉ោងលើ ២៤ម៉ោង។

(ច) រៀបចំបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ការងារសេវាកម្មក្នុងតំបន់រួមមានបទបញ្ជាផ្ទៃក្នុងតំបន់ វិន័យទូទៅរបស់អ្នកវិនិយោគក្នុងតំបន់ និងកំណត់មុខសញ្ញាអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលទទួលឱ្យបោះទីតាំងក្នុងតំបន់តាមគោលការណ៍កំណត់ឱ្យធ្វើសកម្មភាពក្នុងតំបន់។

(ឆ) ធ្វើការឃោសនាទាក់ទាញអ្នកវិនិយោគឱ្យមកធ្វើការវិនិយោគក្នុងតំបន់ និងផ្តល់ព័ត៌មានលំអិតស្តីពីបែបបទ នីតិវិធី និងផលប្រយោជន៍ដែលអ្នកវិនិយោគត្រូវទទួលបានក្នុងការធ្វើវិនិយោគ នៅក្នុងតំបន់របស់ខ្លួន ។

(ជ) ធ្វើការថែទាំ និងជួសជុលបណ្តាហេដ្ឋារចនាសម្ព័ន្ធ ធានាបាននូវគុណភាព និងអនាម័យត្រឹមត្រូវ និងទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់លើរាល់សកម្មភាពមិនប្រក្រតី និងការអនុវត្តខុសពីគោលការណ៍កំណត់របស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

(ឈ) ធ្វើរបាយការណ៍ជូន គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា តាមការតម្រូវ និងអនុវត្តកាតព្វកិច្ចពន្ធដារជូនរដ្ឋ តាមរយៈការកាន់បញ្ជីគណនេយ្យច្បាស់លាស់តាមគំរូណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(ញ) សហការណ៍ និងផ្តល់ការឧបត្ថម្ភនានា ដល់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្នុងកិច្ចដំណើរការរបស់តំបន់ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋអំណាចមូលដ្ឋានដើម្បីដោះស្រាយការងារ ដែលមានការពាក់ព័ន្ធ។

## ជំពូកទី ៤

## ការលើកទឹកចិត្តសម្រាប់តំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៥: នីតិវិធីនៃការលើកទឹកចិត្ត

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាពិនិត្យ និងផ្តល់ការលើកទឹកចិត្តដល់គ្រប់តំបន់សេដ្ឋកិច្ចពិសេសទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា÷

៥.១- សំណើសុំនាំចូលឧបករណ៍សម្ភារៈបរិក្ខារ សម្ភារៈសាងសង់ ដោយរួចពន្ធ សម្រាប់ការងារសាងសង់តំបន់របស់អ្នកអភិវឌ្ឍន៍តំបន់ ត្រូវដាក់ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យ និងសម្រេច ។

៥.២- ការលើកទឹកចិត្តលើការនាំចូល សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ត្រូវសម្រេចផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់តាមសំណូមពរ និង គោលការណ៍នៃច្បាប់ ដោយសាមីអ្នកវិនិយោគក្នុងតំបន់នោះ ត្រូវរៀបចំបញ្ជីសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្មដែលត្រូវសុំនាំចូលទាំងនោះ ដាក់ជូនរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យ ដែលនឹងត្រូវសម្រេចផ្តល់ជូននៅនឹងកន្លែង ហើយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគ្រាន់តែរាយការណ៍ជូនមក គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងស្ថាប័នគ្រប់គ្រង ដើម្បីជ្រាបជាព័ត៌មានប៉ុណ្ណោះ។

៥.៣- សិទ្ធិដែលត្រូវបានទទួលការលើកទឹកចិត្តផ្នែកសារពើពន្ធនឹងសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដែលនឹងត្រូវចេញជូនអ្នកវិនិយោគក្នុងតំបន់ ស្របតាមច្បាប់ និង អនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## មាត្រា ៦: ការលើកទឹកចិត្តផ្នែកសារពើពន្ធ

៦.១ អ្នកអភិវឌ្ឍន៍តំបន់ ត្រូវទទួលបាននូវការលើកទឹកចិត្តទាំងឡាយសម្រាប់សកម្មភាពវិនិយោគដូចតទៅ÷

(ក) ពន្ធលើប្រាក់ចំណេញ: រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ត្រូវបានផ្តល់ជូនសម្រាប់រយៈពេលអតិបរមា ៩ (ប្រាំបួន)ឆ្នាំ ស្របទៅនឹងមាត្រា ១៤ថ្មី ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

(ខ) ពន្ធនាំចូល និងអាករផ្សេងៗ: ការនាំចូលសម្ភារៈបរិក្ខារ សម្ភារៈសាងសង់ ដែលត្រូវប្រើប្រាស់ក្នុងតំបន់សម្រាប់បំរើឱ្យការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ត្រូវបានអនុញ្ញាតដោយពន្ធនាំចូល និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ ។

៦.២ អ្នកវិនិយោគក្នុងតំបន់នឹងទទួលបាននូវការលើកទឹកចិត្តលើពន្ធគយ និងអាករ ដោយអនុលោមទៅតាមមាត្រា ១៤ថ្មី ចំណុច ១៤.៩ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិពាក់ព័ន្ធ ។

៦.៣ អ្នកវិនិយោគក្នុងតំបន់ដែលទទួលបាននូវការលើកទឹកចិត្ត ចំពោះអាករលើតម្លៃបន្ថែមតាមអាត្រា ០(សូន្យ)ភាគរយ ត្រូវបានធ្វើការកត់ត្រាទុកនូវប្រាក់ពន្ធដែលបានលើកលែងនេះសម្រាប់រាល់ករណី

នាំចូលមួយលើកៗរបស់អ្នកវិនិយោគក្នុងតំបន់ ហើយតួរលេខកត់ត្រាប្រាក់ពន្ធនេះនឹងត្រូវលប់ចោលប្រសិនបើធាតុចេញផលិតកម្មត្រូវបាននាំចេញទៅវិញ។ ក្នុងករណីដែលធាតុចេញផលិតកម្មបានបង្វិលនាំចូលទៅទីផ្សារក្នុងស្រុក អ្នកវិនិយោគក្នុងតំបន់ត្រូវបង់សងវិញនូវអាករលើតម្លៃបន្ថែមនេះវិញតាមចំនួនទឹកប្រាក់ដែលបានកត់ត្រាប្រៀបធៀបទៅនឹងបរិមាណដែលបាននាំចេញ។

## មាត្រា ៧: ការលើកទឹកចិត្តដទៃទៀត

៧.១- អ្នកអភិវឌ្ឍន៍តំបន់ត្រូវទទួលបាននូវការនាំចូលដោយរួចពន្ធចំពោះគ្រឿងចក្រសម្ភារៈបរិក្ខារសម្រាប់ការសាងសង់ផ្លូវដែលតភ្ជាប់ពីទីប្រជុំជនទៅតំបន់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាសាធារណៈផ្សេងៗទៀត ដើម្បីផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់តំបន់ផ្ទាល់ ។

៧.២- អ្នកអភិវឌ្ឍន៍តំបន់អាចសុំនាំចូលតាមរូបភាពរួចពន្ធបណ្តោះអាសន្ន (AT) នូវបណ្តា មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីសាងសង់ហេដ្ឋាចនាសម្ព័ន្ធនានាក្នុងដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។

៧.៣- ការនាំចូលទាំងអស់របស់អ្នកអភិវឌ្ឍន៍តំបន់និងអ្នកវិនិយោគក្នុងតំបន់ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៧.៤- អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ និយោជិតបរទេស មានសិទ្ធិផ្ទេរទៅក្រៅប្រទេសនូវរាល់ប្រាក់ចំណូលពីការវិនិយោគ ប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងតំបន់ តាមរយៈធនាគារក្រោយពេលបានបង់ពន្ធរួច។

៧.៥- ក្រៅពីការលើកទឹកចិត្តផ្នែកសារពើពន្ធ អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ មានសិទ្ធិទទួលបាននូវការធានាវិនិយោគ ដូចមានចែងក្នុងមាត្រា ៨ថ្មី មាត្រា៩ និង មាត្រា១០ថ្មី នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

៧.៦- អ្នកអភិវឌ្ឍន៍តំបន់ អាចទទួលបាននូវដីសម្បទានពីរដ្ឋសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ជាប់ព្រំដែន ឬតំបន់ដាច់ស្រយាល ស្របតាមច្បាប់ភូមិបាល ហើយអាចជួលបន្តឱ្យទៅអ្នកវិនិយោគក្នុងតំបន់។

## ជំពូកទី ៥

## វិធានពិសេសទាក់ទងដល់ការគ្រប់គ្រង
## តំបន់ផលិតកែច្នៃនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៨: លក្ខខណ្ឌនៃតំបន់ផលិតកែច្នៃនាំចេញ

តំបន់ផលិតកែច្នៃនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស ជាតំបន់ដែលមានរបងថ្មព័ទ្ធជុំវិញនិងមានច្រកទ្វារចេញ ចូលច្បាស់លាស់ដែលកំណត់ដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

មានតែកម្មករ និយោជិត និយោជក ឬភ្ញៀវ និងភ្នាក់ងារមានសមត្ថកិច្ចដែលមានលិខិតអនុញ្ញាតប៉ុណ្ណោះ ទើបអាចធ្វើដំណើរចេញ ចូលក្នុងបរិវេណតំបន់ និងបរិវេណទីតាំងអ្នកវិនិយោគក្នុងតំបន់បាននៅពេលម៉ោងការងារ។ គ្មានបុគ្គលណាម្នាក់ ទោះបីក្នុងឋានៈណាក៏ដោយអាចស្នាក់នៅក្រៅម៉ោងការងារក្នុងបរិវេណតំបន់ផលិតកែច្នៃនាំចេញ និងបរិវេណទីតាំងអ្នកវិនិយោគក្នុងតំបន់បានឡើយ លើកលែងតែជាសមត្ថកិច្ចយាមប្រចាំការ និង បុគ្គលដែលបានទទួលសិទ្ធិពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

### មាត្រា ៩: ពេលវេលាចេញពី ឬ ចូលក្នុងតំបន់ផលិតកែច្នៃនាំចេញ

ពេលវេលាកំណត់សម្រាប់ការបើកទ្វារឱ្យចេញពី ឬ ចូលក្នុង តំបន់ផលិតកែច្នៃនាំចេញរបស់អ្នកមានភារកិច្ច រាប់ទាំងការនាំចេញ និងការនាំចូលទំនិញ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសតាមរយៈការពិភាក្សាឯកភាពគ្នារវាង អ្នកអភិវឌ្ឍន៍តំបន់ និងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

### មាត្រា ១០: ទំនិញចេញពី ឬ ចូលក្នុងតំបន់កែច្នៃនាំចេញ

ទំនិញដែលធ្វើចរាចរចេញពី ឬ ចូលក្នុង តំបន់ផលិតកែច្នៃនាំចេញ ត្រូវអនុវត្តទៅតាមបទបញ្ជាច្បាស់លាស់ ÷

១០.១-ការនាំទំនិញចេញពី ឬចូលក្នុងបរិវេណតំបន់ផលិតកែច្នៃនាំចេញ ត្រូវបានចាត់ទុកថាជាការនាំទំនិញចេញពី ឬ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចាំបាច់ម្ចាស់ទំនិញត្រូវធ្វើការបំពេញបែបបទនាំចេញ នាំចូល ជាមុនជាមួយភ្នាក់ងារមានសមត្ថកិច្ចប្រចាំការនៅតំបន់ផលិតកែច្នៃនាំចេញ។ ទំនិញទាំងនោះ ត្រូវរៀបចំទុកដាក់ វេចខ្ចប់តាមលក្ខណៈបច្ចេកទេស ដោយត្រូវបិតសៀលត្រឹមត្រូវដោយមន្ត្រីគយ មុននឹងធ្វើការនាំចេញពី ឬនាំចូលក្នុងតំបន់ផលិតកែច្នៃនាំចេញ ។

១០.២- ភ្នាក់ងារមានសមត្ថកិច្ចក្នុងកិច្ចការខាងលើនេះ ត្រូវរៀបចំនូវទម្រង់បែបបទ ដែលមានភាពសាមញ្ញ ងាយស្រួល មានតម្លាភាព និងមិនបង្កការលំបាកដល់ការត្រួតពិនិត្យទំនិញទាំងនោះឡើយ ។

១០.៣- មិនមានការធ្វើពាណិជ្ជកម្មលក់រាយណាមួយអាចបោះទីតាំង ឬធ្វើសកម្មភាពនៅក្នុងតំបន់ផលិតកែច្នៃនាំចេញបានឡើយ ទោះបីក្រោមរូបភាពបំរើផលប្រយោជន៍សង្គម ឬសាធារណៈក៏ដោយ ។

១០.៤- អ្នកវិនិយោគក្នុងតំបន់ ទោះបីសាមីខ្លួនជាម្ចាស់ក៏ដោយមិនអាចយកធាតុចេញផលិតកម្មដែលផលិតនៅក្នុងតំបន់ផលិតកែច្នៃនាំចេញទៅប្រើប្រាស់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសបានឡើយ ។

១០.៥- អ្នកវិនិយោគក្នុងតំបន់ផលិតកែច្នៃនាំចេញ អាចស្នើសុំទៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីធ្វើការទិញទំនិញពីទីផ្សារក្នុងស្រុក ឬពីអ្នកវិនិយោគដែលស្ថិតក្នុងតំបន់ឧស្សាហកម្មទូទៅដើម្បីបំពេញតម្រូវការផលិតកម្ម ដោយត្រូវបំពេញបែបបទកិច្ចសន្យាច្បាស់លាស់ ហើយរាល់ការទិញ លក់នេះត្រូវតែមានការត្រួតពិនិត្យពីភ្នាក់ងារគយប្រចាំតំបន់សេដ្ឋកិច្ចពិសេសទាំងអស់។

ចំពោះការស្នើសុំលក់ចេញទៅទីផ្សារក្នុងស្រុកនូវ ធាតុចេញផលិតកម្ម ដែលខូះ ឬខូចគុណភាព ឬជាទំនិញហួសសម័យដែលអ្នកវិនិយោគក្នុងតំបន់មិនអាចធ្វើការនាំចេញបាន ចាំបាច់អ្នកវិនិយោគក្នុងតំបន់ ត្រូវតែលើកសំណើសុំការសម្រេចដូចគ្នាទៅនឹងការសុំទិញចូលមកក្នុងតំបន់ដែរ ។

រាល់ទំនិញដែលបញ្ចេញទៅលក់នៅទីផ្សារក្នុងស្រុក ទោះបីក្នុងស្ថានភាពណាក៏ដោយ ទំនិញនោះត្រូវបំពេញបែបបទដូចជាទំនិញដែលនាំចូលមកព្រះរាជាណាចក្រកម្ពុជា និងត្រូវវងនូវកាតព្វកិច្ចបង់ពន្ធនាំចូល និងអាករផ្សេងៗទៀតជាធរមាន ។

១០.៦- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មានសិទ្ធិគ្រប់គ្រាន់ និងគ្រប់ពេលវេលា ដើម្បីធ្វើការឆែកឆេរលើរាល់ករណីសង្ស័យទាំងឡាយណា ដែលទាក់ទងទៅនឹងសកម្មភាពមិនប្រក្រតីរបស់អ្នកវិនិយោគក្នុងតំបន់ ក្នុងការនាំចេញ ឬ នាំចូលប្រសិនបើចាំបាច់ និងត្រូវជូនដំណឹងនេះជាផ្លូវការទៅអ្នកអភិវឌ្ឍន៍តំបន់ និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

១០.៧- រាល់ការរំលោភបំពានរបស់អ្នកវិនិយោគក្នុងតំបន់ណាមួយនៃតំបន់ផលិតកែច្នៃនាំចេញ ទៅលើគោលការណ៍នៃការនាំទំនិញខុសទិសដៅកំណត់ ខុសផែនការគ្រប់គ្រងបរិស្ថាន ការរំលោភលើគោលការណ៍ផលិតកម្ម ការផលិតទំនិញមិនស្របច្បាប់ មិនត្រឹមត្រូវស្របតាមបទដ្ឋានស្តង់ដាផលិតឬការយកផលប្រយោជន៍ដែលរដ្ឋបានផ្តល់ឱ្យទៅប្រើខុសទិសដៅ គឺជាកម្មវត្ថុដែលត្រូវទទួលរងនូវការដាក់ពិន័យ និងទោសទណ្ឌទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

## ជំពូកទី ៦

## កម្លាំងពលកម្ម

### មាត្រា ១១: ការប្រើប្រាស់ និងការគ្រប់គ្រងកម្លាំងពលកម្ម

ការប្រើប្រាស់ និងការគ្រប់គ្រងកម្លាំងពលកម្មនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានធានានូវសិទ្ធិ និងការការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ កម្មករ និយោជិត ដែលបម្រើការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានទទួលនូវកម្រិតប្រាក់ឈ្នួល សិទ្ធិ និងផលប្រយោជន៍ សុវត្ថិភាពការងារ និងលក្ខខណ្ឌនៃការថែរក្សាសុខភាព ដូចបានកំណត់ក្នុងច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី ការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

ការជួលអ្នកគ្រប់គ្រង អ្នកបច្ចេកទេស ឬអ្នកជំនាញការពីបរទេសអាចអនុវត្តបាន សម្រាប់តែករណីដែលចំនួនអ្នកបម្រើការងារជាជនជាតិបរទេសនោះ
មិនមានចំនួនលើសពី១០(ដប់)ភាគរយនៃចំនួនសរុប របស់បុគ្គលិក កម្មករ និយោជិតរបស់ខ្លួនប៉ុណ្ណោះ។

អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សញ្ជាតិបរទេស អាចនាំយកមកជាមួយនូវសហព័ទ្ធ អ្នកក្នុងបន្ទុករបស់ខ្លួន និងមានសិទ្ធិទទួលបាននូវទិដ្ឋាការស្នាក់នៅ ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា ។

រាល់ការប្រើប្រាស់កម្លាំងពលកម្ម តាមរយៈការជ្រើសរើស និង ជួលកម្មករ និយោជិតខ្មែរ ឬកម្លាំងពលកម្មបរទេស តាមអត្រាកំណត់ខាងលើ និងការនាំយកមកនូវអ្នកក្នុងបន្ទុក ត្រូវអនុវត្ត ឱ្យបានស្របតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី ៧

## ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

### មាត្រា ១២: ការបណ្តុះបណ្តាល

អ្នកអភិវឌ្ឍន៍តំបន់មានភារកិច្ចសហការណ៍ ជាមួយក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កលក្ខណៈបណ្តុះបណ្តាលដល់ កម្មករ និយោជិតខ្មែរ បង្កើនការយល់ដឹងនិងបច្ចេកទេសថ្មីៗដល់កម្មករ និយោជិតទាំងនោះតាមកម្មវិធីច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី ៨

## ដំណោះស្រាយវិវាទ និង ការរំលោភបំពាន

### មាត្រា ១៣:

តំបន់សេដ្ឋកិច្ចពិសេស ដែលបោះទីតាំងនៅលើទឹកដីនៃខេត្ត ក្រុងណាមួយនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការខេត្ត ក្រុងនោះ សម្រាប់ករណីដែលមានការរំលោភបំពាននានា រួមទាំងករណីបទល្មើសព្រហ្មទណ្ឌដែលកើតមានផង ។

### មាត្រា ១៤:

អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ កម្មករ និយោជិត និយោជក និងមន្ត្រីរាជការណាដែលធ្វើសកម្មភាព និងបំពេញការងារនៅក្នុងតំបន់ ហើយបានរំលោភបំពានទៅនឹងបទបញ្ជាទាំងឡាយ ដែលបានកំណត់ក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះនឹងត្រូវទទួលរងទោសទណ្ឌ ទៅតាមច្បាប់ជាធរមាន ។

មន្ត្រីរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសត្រូវហាមឃាត់មិនឱ្យជ្រៀតជ្រែកចូលកិច្ចការអភិវឌ្ឍន៍របស់តំបន់ឡើយ។

បុគ្គលដែលជាមន្ត្រីរាជការ ដែលអនុវត្តខុសពីតួនាទី និងសិទ្ធិអំណាចដែលបានប្រគល់ជូនដោយក្រសួង ស្ថាប័នគ្រប់គ្រង ត្រូវទទួលនូវទោស ស្របទៅតាមមាត្រាទាំងឡាយនៃច្បាប់ស្តីពី សហលក្ខន្តិកៈនៃមន្ត្រីរាជការជាធរមាន។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

### មាត្រា ១៥:

បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធនានា ត្រូវយកមកអនុវត្តលើរាល់សកម្មភាពនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងករណីដែលបញ្ញត្តិនៃអនុក្រឹត្យនេះមិនបានបញ្ជាក់ ។

### មាត្រា ១៦:

អនុក្រឹត្យនេះ ត្រូវធ្វើបច្ចុប្បន្នភាពទៅតាមសភាពការណ៍ និងតម្រូវការជាក់ស្តែងនាពេលអនុវត្ត

តាមសំណើរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងមានការយល់ព្រមពីគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេស ព្រមជាមួយត្រូវរៀបចំឱ្យទៅជាទម្រង់ច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេសមួយ ដើម្បីធានាបាននូវតម្លាភាព និងទំនុកចិត្តពីអ្នកវិនិយោគនាពេលដ៏ឆាប់ខាងមុខ។

**មាត្រា ១៧ៈ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អភិបាលគ្រប់ខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួល អនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជម្រាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ១៧
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា មួយ.-**

មាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ត្រូវបានកែសម្រួលដូចតទៅ :

**មាត្រា ២ ថ្មី.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| - ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| - ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីទទួលបន្ទុកការងារ AMBDC | សមាជិក |

- រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — សមាជិក
- អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងផែនការ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ — សមាជិក
- តំណាង គណៈកម្មាធិការព្រំដែន — សមាជិក
- អគ្គលេខាធិការរង អាជ្ញាធរកំចាត់មីនកម្ពុជា — សមាជិក
- អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ — សមាជិក
- ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា — សមាជិកអចិន្ត្រៃយ៍

**មាត្រា ៣ ថ្មី.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានក្រុមការងារបច្ចេកទេសមួយជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

- ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា — ប្រធាន
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — អនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — អនុប្រធាន
- ប្រធាននាយកដ្ឋាន គមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក

| | |
|---|---|
| - ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - ប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ | សមាជិក |
| - តំណាង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាង ក្រសួងបរិស្ថាន | សមាជិក |
| - តំណាង ក្រសួងការពារជាតិ | សមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| - នាយក ផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា | សមាជិក |
| - អភិបាលស្រុកពាក់ព័ន្ធ | សមាជិក |
| - នាយករងរដ្ឋបាលទទួលបន្ទុកការិយាល័យផែនការ-ស្ថិតិ រអយក | លេខាធិការអចិន្ត្រៃយ៍ |

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការព្រំដែន អាជ្ញាធរកំចាត់មីនកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក ដែលមានចែងក្នុងមាត្រា ២ថ្មី និង មាត្រា ៣ថ្មី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*

*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*

*ដូចមាត្រា បី*

*ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...១២០៨...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សាលាខេត្តកោះកុង

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Mr.HERBERT RAWLINGS, Benefactor , Together With the Rawlings Foundation ដែលបានឧបត្ថម្ភថវិកា ចំនួន ១០.០០០ USD ចូលរួមជួយកសាងសាលារៀន នៅភូមិគីរីវង្ស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១០៩...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ០៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

-លោក **សេង គឹមសាន** ប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ឧត្តរមានជ័យ

**ខ.មេដាយប្រាក់ការងារ :**

-លោក **សុខ ហុន** អនុប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តឧត្តរមានជ័យ

**គ.មេដាយសំរិទ្ធការងារ :**

-លោក **តិន គឹមសុខ** ប្រធានការិយាល័យ សុខុមាលភាពកុមារ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តឧត្តរមានជ័យ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១២ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៥១០...អនក្រ.បក.៣៣

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៛៘

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋ ចំនួន២០៤រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន ស្រុកបាទី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឆ្លោក | ផន | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា |
| ២-លោក | ម៉ៅ | វណ្ណឈាន | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងជំនួយការឯ.ឧ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៣-លោក | ជា | វន្នី | ប្រធានសាខាគយ ប្រចាំខេត្តស្វាយរៀង |
| ៤-លោក | សរ | រតនា | ប្រធានការិយាល័យគណនេយ្យ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៥-លោក | ឡាយ | គួក | ប្រធានការិយាល័យហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៦-លោក | ឡុង | សារិន | អនុប្រធានមជ្ឈមណ្ឌល O.S.P |
| ៧-លោក | សាន | ស៊ីដា | កងការពារ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៨-លោក | មាស | ចាន់រក្សា | មន្ត្រីនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា |
| ៩-លោក | ធ្លាក់ | សុខុម | មន្ត្រីក្រសួងពតិមាន |
| ១០-លោក | ម៉េង | មុយ | អ្នកបើកបររថយន្ត ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ១១-លោក | អ៊ឹម | វត្ថា | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ១២-លោក | រ៉ាំង | ចាន់រិទ្ធី | ប្រធានមជ្ឈមណ្ឌលខ្សែខាងក្រៅ នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |

១៣-លោក នង ផុល ប្រធានមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ ប័ណ្ណស័ព្ទ នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

១៤-លោក អ៊ុក ជូរ៉ានី ប្រធានមជ្ឈមណ្ឌលទូរស័ព្ទ FETEX 150 នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

១៥-លោក ជា សំណាង ប្រធានបច្ចេកទេសក្រុមហ៊ុន CAMINTEL

១៦-លោក ហេង វណ្ណារិន ប្រធានរដ្ឋបាល ចាត់ការទូទៅក្រុមហ៊ុន CAMINTEL

១៧-លោកស្រី និត្យ ចំន្ទភារិន ប្រធានការិយាល័យវិក័យប័ត្រទូទៅអន្តរជាតិ

១៨-លោក ព្រាប សុរីន្ទ ប្រធាននាយកដ្ឋានប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១៩-លោកស្រី អាន គីមឈុន អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២០-លោក យី វណ្ណបូនិ ប្រធានការិយាល័យ គណនេយ្យទូទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២១-លោក ប្រាក់ សៀងអាន ប្រធានការិយាល័យ បញ្ញើសារ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២២-លោក សូ អ៊ិត ប្រធានការិយាល័យ តែមប្រិយវិទ្យា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៣-លោក គីម សំខាន់ អនុប្រធានមជ្ឈមណ្ឌលជួសជុលបណ្តាញទូរស័ព្ទ

២៤-លោក អ៊ូច- សុខុម ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៥-លោក រ៉ូវ សុខយូ អនុប្រធានផ្នែកបញ្ញើឆាប់រហ័ស

២៦-លោក ហេង គា អនុប្រធានការិយាល័យអធិការកិច្ច នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៧-លោក អេង ចៅ អនុប្រធានការិយាល័យផែនការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៨-លោក ប្រាក់ គារ៉ាវុធ ប្រធានការិយាល័យផែនការ ហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៩-លោកស្រី លឹម លឿង ប្រធាននាយកដ្ឋានគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៣០-លោក ឡា ឡៀ មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តតាកែវ

៣១-លោក គឹង ចាន់ឈី ប្រធានមន្ទីរ ហិរញ្ញវត្ថុ ខេត្តតាកែវ

៣២-លោក ភង វិគុណ ប្រធានមន្ទីរ ផែនការ ខេត្តតាកែវ

៣៣-លោក សុខ ប៉ុណ្ណា អនុប្រធានមន្ទីរ អភិវឌ្ឍន៍ជនបទ ខេត្តតាកែវ

៣៤-លោក រស់ សម្បត្តិ មេបញ្ជាការរង កងរាជអាវុធហត្ថ ខេត្តតាកែវ

៣៥-លោក ឆេ ស៊ុនឌី នាយក្រុមការ សាលាស្រុកបាទី ខេត្តតាកែវ

៣៦-លោក ឡាយ សុខា អភិបាលស្រុកបាទី ខេត្តតាកែវ

៣៧-លោក ចាន់ សារី អធិការនគរបាលស្រុកបាទី ខេត្តតាកែវ

៣៨-លោក អ៊ូ សុខជា អភិបាលរងស្រុកបាទី ខេត្តតាកែវ

៣៩-លោក ឡាំង វាសនា អភិបាលរងស្រុកបាទី ខេត្តតាកែវ

៤០-លោក សុខ សាចាន់ មន្ត្រីចូលនិវត្តន៍ ស្រុកបាទី ខេត្តតាកែវ

៤១-លោក នៅ ឈុនលី ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ

៤២-លោក ម៉ែន ថាច អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ

៤៣-លោក ឱន ម៉ុនថន ប្រធានមន្ទីរស្រុកបាទី ខេត្តតាកែវ

៤៤-លោក គង់ សំអូន ស្នងការរងនគរបាល ខេត្តតាកែវ

៤៥-លោក ញៀម ហ៊ែល មន្ត្រីចូលនិវត្តន៍ ស្រុកបាទី ខេត្តតាកែវ

៤៦-លោក ម៉េង ម៉ារ៉ាដា មេបញ្ជាការកងរាជអាវុធហត្ថ ស្រុកបាទី ខេត្តតាកែវ

៤៧-លោក អ៊ុំ សារ៉ុន ប្រធានការិយាល័យផែនការ ស្រុកបាទី ខេត្តតាកែវ
៤៨-លោក អ៊ួង ឡេង ប្រធានការិយាល័យធម្មការ និងសាសនា ស្រុកបាទី ខេត្តតាកែវ
៤៩-លោក ពៅ ថៃ មន្ត្រីចូលនិវត្តន៍
៥០-លោក ឆេ សយ មេឃុំលំពង ស្រុកបាទី ខេត្តតាកែវ
៥១-លោក គ្រី រដ្ឋ នាយករងវិទ្យាល័យ សុខ អាន ត្រាំខ្នារ ស្រុកបាទី ខេត្តតាកែវ
៥២-លោក ឃង់ ថៃ មេឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ
៥៣-លោក ឃួត ខួន សមាជិកក្រុមប្រឹក្សា ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ
៥៤-លោក នៅ នន់ សមាជិកក្រុមប្រឹក្សា ឃុំពារាម ស្រុកបាទី ខេត្តតាកែវ
៥៥-លោក ជួប សុជាប មេឃុំសូភី ស្រុកបាទី ខេត្តតាកែវ
៥៦-លោក ឈឹម តិច សមាជិកក្រុមប្រឹក្សា ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ
៥៧-លោក ចាន់ យ៉ែម មេឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ
៥៨-លោក ស្រី ស្រឿង មេឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ
៥៩-លោក ប៊ុល ជុស មេឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ
៦០-លោក ជិន អ៊ុម មេឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ
៦១-លោកស្រី ម៉ែន សយ អនុប្រធានការិយាល័យកិច្ចការនារី ស្រុកបាទី ខេត្តតាកែវ
៦២-លោកស្រី ឈឹន សុវណ្ណា ប្រធានការិយាល័យកិច្ចការនារី ស្រុកបាទី ខេត្តតាកែវ
៦៣-លោក អ៊ុច តៀ មេឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ
៦៤-លោក ហែម នួច មេឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ
៦៥-លោក នួច សឿន មេឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ
៦៦-លោក ឌិច ឃួន មេឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ
៦៧-លោក ទង់ ទ៉ាន មេឃុំពារាម ស្រុកបាទី ខេត្តតាកែវ
៦៨-លោក ហេង ហុង មេឃុំត្នោត ស្រុកបាទី ខេត្តតាកែវ

**ខ_មេដាយប្រាក់ការងារ :**

១-លោក ហែម យ៉ុន អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
២-លោក ណី សំកុល អនុប្រធានការិយាល័យអាជីវកម្ម នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៣-លោកស្រី ខុន ចណ្ណី អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៤-លោកស្រី អ៊ុក ផលនារី ប្រធានផ្នែករបៀបនិងពិធីការ ការិ.រដ្ឋបាល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៥-លោកស្រី ឌិច ពិសិដ្ឋ ប្រធានផ្នែកគ្រប់គ្រងបុគ្គលិក ការិ.រដ្ឋបាល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៦-លោកស្រី ម៉ែន ចណ្ណាម៉ូលី ប្រធានផ្នែករបាយការណ៍ ការិ.រដ្ឋបាល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៧-លោកស្រី ម៉ូដេត មុនីឧត្តរា អនុប្រធានផ្នែកអាជីវកម្មទីផ្សារ ប័ណ្ណស័ព្ទ មជ្ឈមណ្ឌលសាធារណៈ ប័ណ្ណស័ព្ទ
៨-លោក ឈោ ស៊ីដារិទ្ធ ប្រធានក្រុមគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលបណ្តាញខ្សែខាងក្រៅ
៩-លោក តឹប គឹមញ៉ាន នាយកវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន បាទី ខេត្តតាកែវ
១០-លោក អ៊ូ ឈន មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ
១១-លោក សេង វេនា ប្រធានការិយាល័យស្រុកប្រតិបត្តិ បាទី ខេត្តតាកែវ
១២-លោក ឃិន ប៊ូ ប្រធានការិយាល័យដែនដី នគរូបនីយកម្មនិងសំណង់ ស្រុកបាទី ខេត្តតាកែវ
១៣-លោក ស្វាយ សំអឿន មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ

| | | | |
|---|---|---|---|
| ១៤-លោក | ជា | ចាន់លី | មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ |
| ១៥-លោក | ស្មៅ | ឈឿន | អធិការរងនគរបាល ស្រុកបាទី ខេត្តតាកែវ |
| ១៦-លោក | ខាត់ | ឱន | អធិការរងនគរបាល ស្រុកបាទី ខេត្តតាកែវ |
| ១៧-លោក | ជា | យ៉ុន | អធិការរងនគរបាល ស្រុកបាទី ខេត្តតាកែវ |
| ១៨-លោក | ទ៉ុង | ចាន់ថន | ប្រធានការិយាល័យកសិកម្ម ស្រុកបាទី ខេត្តតាកែវ |
| ១៩-លោក | ណារ៉ា | សុផាត | អនុប្រធានការិយាល័យរដ្ឋបាល ស្រុកបាទី ខេត្តតាកែវ |
| ២០-លោក | ម៉ិច | គឹមឆុន | មន្ត្រីការិយាល័យស្រុកប្រតិបត្តិ បាទី ខេត្តតាកែវ |
| ២១-លោក | ម៉ៅ | ឈឿន | មន្ត្រីការិយាល័យស្រុកប្រតិបត្តិ បាទី ខេត្តតាកែវ |
| ២២-លោក | ម៉ា | តួច | សមាជិកក្រុមប្រឹក្សាឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ |
| ២៣-លោក | អឿ | អឿន | ប្រជាជនឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ |
| ២៤-លោក | អួន | សុខេត្ត | សមាជិកក្រុមប្រឹក្សាឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ |
| ២៥-លោក | ជា | សុខហឿង | សមាជិកក្រុមប្រឹក្សាឃុំសូភី ស្រុកបាទី ខេត្តតាកែវ |
| ២៦-លោក | អ៊ុង | សុខ្ល | ជំទប់ទី១ ឃុំដូង ស្រុកបាទី ខេត្តតាកែវ |
| ២៧-លោក | សន | សារុត | សមាជិកក្រុមប្រឹក្សាឃុំលំពង់ ស្រុកបាទី ខេត្តតាកែវ |
| ២៨-លោក | គឹម | សុខ | ប្រធានការិយាល័យរដ្ឋបាល សាលាស្រុកបាទី ខេត្តតាកែវ |
| ២៩-លោក | ម៉ុល | សុត | ជំទប់ទី១ ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ |
| ៣០-លោក | ស្រី | សំបូរ | សមាជិកក្រុមប្រឹក្សាឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ |
| ៣១-លោក | ហែម | ម៉្រឹង | សមាជិកក្រុមប្រឹក្សាឃុំត្នោត ស្រុកបាទី ខេត្តតាកែវ |
| ៣២-លោក | ម៉ុញ | ចន | ជំទប់ទី១ ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ |
| ៣៣-លោក | ហ៊ីង | យឹម | ជំទប់ទី១ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ |
| ៣៤-លោក | អយ | ម៉េន | សមាជិកក្រុមប្រឹក្សាឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ |
| ៣៥-លោក | ឡេង | កេង | អនុប្រធានការិយាល័យសេដ្ឋកិច្ច សាលាស្រុកបាទី ខេត្តតាកែវ |
| ៣៦-លោក | ប្រាក់ | ចាន់ថុល | ប្រធានការិយាល័យសេដ្ឋកិច្ច សាលាស្រុកបាទី ខេត្តតាកែវ |
| ៣៧-លោក | សោ | សុខុម | អនុប្រធានការិយាល័យសង្គមកិច្ច សាលាស្រុកបាទី ខេត្តតាកែវ |
| ៣៨-លោក | អ៊ុន | ម៉ាន | មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ |
| ៣៩-លោក | យាត | មារុត | មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាទី ខេត្តតាកែវ |
| ៤០-លោក | ណុប | មាន | អនុប្រធានមន្ទីរស្រុកបាទី ខេត្តតាកែវ |
| ៤១-លោក | ម៉ី | ឈឿន | នាយករងវិទ្យាល័យ ហ៊ុន សែន ១ មិថុនា |
| ៤២-លោក | ម៉េន | សឿន | នាយករងវិទ្យាល័យ ទន្លេបាទី |
| ៤៣-លោក | ចាន់ | សុខន | នាយកសាលាបឋមសិក្សា ក្រាំងពង្រ |
| ៤៤-លោក | អ៊ុន | អាត | អធិការរងនគរបាល ស្រុកបាទី ខេត្តតាកែវ |
| ៤៥-លោក | យូ | សយ | នាយកសាលាបឋមសិក្សា ប្រាសាទស្រះកែវ |
| ៤៦-លោក | ឈុយ | សំអឿន | នាយកសាលាបឋមសិក្សា សុរភី |
| ៤៧-លោកស្រី | នូ | សុខនា | សមាជិកក្រុមប្រឹក្សាឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ |

**គ-មេដាយសំរឹទ្ធការងារ :**

១-លោក នៅ ណារិន មន្ត្រីការិយាល័យកសិកម្ម ស្រុកបាទី ខេត្តកែវ
២-លោក យឹម សារាវុធ នាយកសាលាបឋមសិក្សា អូរព័ទ្ធ
៣-លោក ឆឺរ សុខុន មន្ត្រីចូលនិវត្តន៍
៤-លោក ឡូច ម៉ាត បុគ្គលិកសិក្សាសាលាបឋមសិក្សា ត្រគៀត
៥-លោក សុខ សារឹម នាយកសាលាបឋមសិក្សា ដីក្រហម
៦-លោក ឆេស សុខ នាយកសាលាបឋមសិក្សា ទន្លេបាទី
៧-លោក គុយ សឿន នាយករងសាលាបឋមសិក្សា ទន្លេបាទី
៨-លោក គី គៀង បុគ្គលិកសិក្សាសាលាបឋមសិក្សា អង្គបរិច្ឆាគ
៩-លោក អ៊ូ វង់ មន្ត្រីចូលនិវត្តន៍
១០-លោក ម៉ើញ សុខ បុគ្គលិកសិក្សាវិទ្យាល័យ ទន្លេបាទី
១១-លោក កែវ- ម៉ោង នាយករងសាលាបឋមសិក្សា ព្រៃជា
១២-លោក ឡឹក សុខា ប្រជាជន
១៣-លោក អ៊ុំ ភាន នាយករងសាលាបឋមសិក្សា ពញ្ញាគុក
១៤-លោក ឆឹង ជួន មន្ត្រីចូលនិវត្តន៍
១៥-លោក អ៊ិន ចាន់ធី នាយកអនុវិទ្យាល័យ ឈើទាលជ្រំ
១៦-លោក ចិន ទ៉ង់ នាយករងសាលាបឋមសិក្សា ក្រាំងពង្រ
១៧-លោក សួន ជួន មន្ត្រីចូលនិវត្តន៍
១៨-លោក ជួន ឈុំ នាយកសាលាបឋមសិក្សា បាក់រនាស់
១៩-លោក ចំបក់ ឆ៊ែត បុគ្គលិកសិក្សាវិទ្យាល័យ សុខ អាន ត្រាំខ្នារ
២០-លោក ស្វាយ ម៉េង មន្ត្រីចូលនិវត្តន៍
២១-លោក ឡៀម ជួន នាយកសាលាបឋមសិក្សា ផ្ទស
២២-លោក លីម ហួត នាយករងវិទ្យាល័យ សុខ អាន ត្រាំខ្នារ
២៣-លោក នូ សំអាត នាយករងវិទ្យាល័យ សុខ អាន ត្រាំខ្នារ
២៤-លោក មុំ ដា មន្ត្រីមន្ទីរហិរញ្ញវត្ថុ ខេត្តតាកែវ
២៥-លោក សួស សារិទ្ធ នាយកសាលាបឋមសិក្សា ត្រាំខ្នារ
២៦-លោក នួន ណាន នាយកសាលាបឋមសិក្សា ភ្នំតូច
២៧-លោក ខ្មៅ រ៉ុម នាយកសាលាបឋមសិក្សា អង្គតាភោគ
២៨-លោក ពៅ ចាន់ថន បុគ្គលិកសិក្សាសាលាបឋមសិក្សា អង្គតាភោគ
២៩-លោក ឈឹម សុខ នាយករងសាលាបឋមសិក្សា អង្គតាភោគ
៣០-លោក សុខ សារួន នាយកសាលាបឋមសិក្សា ចំប៉ា
៣១-លោក ឡាច ឆន នាយកវិទ្យាល័យ សុខ អាន ត្រាំខ្នារ
៣២-លោក ផាន់ សារី មន្ត្រីការិយាល័យ កសិកម្ម ស្រុកបាទី ខេត្តតាកែវ
៣៣-លោក ឯម ឫទ្ធិ មន្ត្រី សាលាស្រុកបាទី ខេត្តតាកែវ
៣៤-លោក ស៊ូ ម៉ាត ប្រធានការិយាល័យឧស្សាហកម្ម ស្រុកបាទី ខេត្តតាកែវ
៣៥-លោក មៀច នា ប្រធានការិយាល័យបរិស្ថាន ស្រុកបាទី ខេត្តតាកែវ

| | | | |
|---|---|---|---|
| ៣៦-លោក | មួង | អន្ថារ៉ា | មន្ត្រីការិយាល័យ ប្រតិបត្តិ ស្រុកបាទី ខេត្តតាកែវ |
| ៣៧-លោក | អ៊ុក | រ៉ែ | អនុប្រធានការិយាល័យផែនការ ស្រុកបាទី ខេត្តតាកែវ |
| ៣៨-លោក | សន | សុធី | ប្រធានការិយាល័យពន្ធដារ ស្រុកបាទី ខេត្តតាកែវ |
| ៣៩-លោក | ឆេង | មី | នាយករងវិទ្យាល័យ ហ៊ុន សែន ១មិថុនា |
| ៤០-លោក | ពេជ្រ | សុផុន | នាយកសាលាបឋមសិក្សា ភ្នំតូច |
| ៤១-លោក | ម៉ាន់ | ចន្ធី | នាយកសាលាបឋមសិក្សា ឆាត់ |
| ៤២-លោក | ពៅ | សុខុធ | នាយកសាលាបឋមសិក្សា អង្គ |
| ៤៣-លោក | អ៊ុក | សំបូរ | បុគ្គលិកសិក្សាវិទ្យាល័យ ហ៊ុន សែន ១មិថុនា |
| ៤៤-លោក | ហេង | សុខា | នាយករងវិទ្យាល័យ ហ៊ុន សែន ១មិថុនា |
| ៤៥-លោក | ទៀច | កុសល | មន្ត្រីចូលនិវត្តន៍ |
| ៤៦-លោក | ម៉ក់ | មិន | នាយកសាលាបឋមសិក្សា ផ្ទុទ្រព្យ |
| ៤៧-លោក | គោគ | រ៉ុន | បុគ្គលិកសិក្សាសាលាបឋមសិក្សា បន្ទាយរី |
| ៤៨-លោក | ម៉ូ | សារឿន | នាយកសាលាបឋមសិក្សា ចក |
| ៤៩-លោក | អ៊ួង | ម៉ុនសឿ | នាយកសាលាបឋមសិក្សា កំណប់ |
| ៥០-លោក | ឈួង | ម៉ែត | នាយកសាលាបឋមសិក្សា ប្រាសាទ |
| ៥១-លោក | ទ្រាក់ | ឡុង | មន្ត្រីចូលនិវត្តន៍ |
| ៥២-លោក | ទង | ទង់ | មន្ត្រីចូលនិវត្តន៍ |
| ៥៣-លោក | ពេជ្រ | ស៊ីវន | មន្ត្រីចូលនិវត្តន៍ |
| ៥៤-លោក | មាស | តេង | មន្ត្រីចូលនិវត្តន៍ |
| ៥៥-លោក | សេក | ឌីន | នាយកសាលាបឋមសិក្សា សិរីជោតវ័ន |
| ៥៦-លោក | ស៊ឹម | សំបូរ | នាយកសាលាបឋមសិក្សា ចាន់ សារុន សម្ពោធិញ្ញាណ |
| ៥៧-លោក | ឌុំ | ស៊ីផូ | នាយកសាលាបឋមសិក្សា ដូនកែវមុនី |
| ៥៨-លោក | អ៊ុច | ពូល | នាយកសាលាបឋមសិក្សា ហាំង ង៉ោ ស្មៅខ្ចី |
| ៥៩-លោក | ម៉ែន | សារឿន | នាយកសាលាបឋមសិក្សា បន្ទាយត្រាវ |
| ៦០-លោក | យិន | យ៉ុម | នាយកសាលាបឋមសិក្សា ឃ្លាំងសៀម |
| ៦១-លោក | ឃួន | សឿន | ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំកណ្តឹង |
| ៦២-លោក | ក្រាយ | នួន | មន្ត្រីនគរបាល ស្រុកបាទី ខេត្តតាកែវ |
| ៦៣-លោក | អ៊ឹម | វណ្ណារ៉ា | ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំសូភី |
| ៦៤-លោក | ឈុប | ស៊ីម៉ុន | ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំកុមាររាជា |
| ៦៥-លោក | ឡុង | ចៅ | ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំលំពង់ |
| ៦៦-លោក | ជា | យូរ៉ាន់ | ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំត្រពាំងក្រសាំង |
| ៦៧-លោក | អ៊ូ | គា | អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំត្រពាំងក្រសាំង |
| ៦៨-លោកស្រី | ហែម | ផាណា | នាយិកាសាលាបឋមសិក្សា ធំបក់ |
| ៦៩-លោកស្រី | សារី | សាខន | បុគ្គលិកសិក្សា សាលាបឋមសិក្សា ដូងកែវមុនី |
| ៧០-លោកស្រី | ឡាយ | បូរិន | នាយិការងសាលាបឋមសិក្សា បន្ទាយត្រាវ |

៧១-លោក ខាត់ ថុង ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧២-លោក សឿង សុផុន ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៣-លោក ឈុម ជា អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៤-លោក ហែម ឡេង ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៥-លោក ជុំ មុត អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៦-លោក ឌុក សុខឿន ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៧-លោក ឈន ទ្រឿន អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៨-លោក ឡឹក វិសាល អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៧៩-លោក ជួប សុផុន អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៨០-លោក ខៀវ សារី អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៨១-លោក ខឹន ម៉ាន អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៨២-លោក នួន វណ្ណារ៉ា ប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៨៣-លោក លី សារុំ អនុប្រធានប៉ុស្តិ៍រដ្ឋបាល ឃុំ
៨៤-លោក ហួន សារឿន ប្រធានផ្នែកព្រហ្មទណ្ឌ
៨៥-លោក ឃុត ឡូ អនុប្រធានផ្នែកព្រហ្មទណ្ឌ
៨៦-លោក ចាប សុខុម ប្រធានផ្នែកចរាចរ
៨៧-លោក អ៊ឹម និត អនុប្រធានផ្នែកចរាចរ
៨៨-លោក ផាន និត ប្រធានផ្នែកសរុប
៨៩-លោក សុខ វណ្ណធឿន អនុប្រធានផ្នែកសន្តិសុខ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៥១១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនមន្ត្រីរាជការ ចំនួន១១រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាង អភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ ជូនប្រជាពលរដ្ឋ ក្នុងមូលដ្ឋានស្រុកបាទី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ភុយ ពុំ** អគ្គនាយករដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២-ឯកឧត្តម **ឆូច ហេង** អគ្គនាយកទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៣-លោក **មាស ប៊ូ** អគ្គនាយករងប្រៃសណីយ៍ និងទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៤-លោក **ញឹក កោសល្យវិទ្យា** អគ្គនាយកក្រុមហ៊ុន CAMINTEL.

៥-លោក **កែវ ឧត្ដារិន** អគ្គនាយករងរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៦-លោក **ស៊ឹម ធី** អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៧-លោក **ជួន ដារ៉ូ** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៨-លោក **ចែម សខ្វារ** អនុប្រធាននាយកដ្ឋានអធិការកិច្ច នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៩-លោក **ឆួក ដារិទ្ធ** ប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១០-លោក **ឆេព ម៉ីន្ថា** អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១១-លោក **ផ្ទូខ ឆូម៉ា** ប្រធានការិយាល័យបញ្ជើឆាប់រហ័ស

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧១៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនឧកញ៉ា **ប៊ុត ចាន់ធូ** ប្រធានឡូត៍នេសាទ លេខ ១៨ ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានគុណបំណាច់ក្នុងការជួយកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងវិស័យកសិកម្ម នៅស្រុកល្វាឯម ខេត្តកណ្តាល ចំណាយអស់ថវិកាសរុបចំនួន ១៤៦.៧៣១ ដុល្លារ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី … ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល ៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩១៣...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

-វរសេនីយ៍ឯក **ហ៊ឹម សារ៉ាន់** នាយរងមណ្ឌល ក២ កងទ័ពជើងគោក ប្រចាំយោធភូមិភាគពិសេស ថវិកាចំនួន ១២៤.៧៤២ ដុល្លារ

**ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

-លោកជំទាវ **ស្រី តូច _ ហាក់ ម៉ិនឌៀន** ថវិកាចំនួន ៧៩.៣៧៥ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៦១៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជួយទប់ស្កាត់នូវការផលិត ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

១-លោក **ពឹង ស៊ីវុត្ថា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

២-លោកស្រី **អ៊ីវ ស្រី** ប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាល

**ខ.មេដាយប្រាក់ការងារ :**

១-លោក **ឯម ហ៊ីយ** អនុប្រធាននាយកដ្ឋានទីតិកម្មអប់រំ និងបង្ការការពារ

២-លោកស្រី **ឈឹម សិទ្ធិបុណ្យរិទ្ធិ** ប្រធានការិយាល័យមន្ទីរពិសោធន៍

៣-លោក **អ៊ុក ស៊ីផាន់** អនុប្រធានការិយាល័យ នាយកដ្ឋានទីតិកម្ម អប់រំ និង បង្ការការពារ

៤-លោក **ទី ម៉ុច** អនុប្រធានការិយាល័យ នាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០២គ្រឿង ជូនសប្បុរសជន ដែលបានឧបត្ថម្ភថវិកា ជួយកសាង អគារសាលាមត្តេយ្យ ០១ខ្នង មាន០៣បន្ទប់ ស្ថិតក្នុងបរិវេណសាលាបឋមសិក្សាថ្មគោល ក្នុងឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

- *Mr. Kim Sung Jeon* សប្បុរសជន កូរ៉េ បានឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

- លោក ម៉ៅ ស៊ី នៅក្រុងភ្នំពេញ ឧបត្ថម្ភថវិកា ចំនួន ៥.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៩១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី **Lena Ricther** ប្រធានអង្គការ **Save The Children Norway** ប្រចាំកម្ពុជា ដែលមានគុណបំណាច់ខ្ពស់ ក្នុងការជួយកសាង និងអភិវឌ្ឍន៍ វិស័យអប់រំ នៅខេត្តព្រះវិហារ តាមរយៈការជួយសាងសង់អគារសិក្សាចំនួន ២៨ខ្នង ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកចំនួន ០៧ខ្នង រួមទាំងការបំពាក់សម្ភារៈ និងសម្ភារឹមសិក្សាផ្សេងៗផង ចំណាយ អស់ទឹកប្រាក់ សរុបចំនួន ៩៨២.៧២៦ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...១៥១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
៦-ឧបាសិកា សែ ផ្លយ ថវិកាចំនួន ៥.៥០០ ដុល្លារ
៧-លោក កើត បូរ ថវិកាចំនួន ៥.៥០០ ដុល្លារ
៨-លោក ដែង ឈុន ថវិកាចំនួន ៥.២៣១ ដុល្លារ
៩-លោក ប៊ុន រឿន ថវិកាចំនួន ៥.១២៣ ដុល្លារ
១០-លោក អ៊ិន សន ថវិកាចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោកស្រី មួន ថងបៃ ថវិកាចំនួន ៤.៩៥៦ ដុល្លារ
២-លោកស្រី ឈួន អនស៊ី ថវិកាចំនួន ៤.៥០០ ដុល្លារ
៣-លោក កែត ឈឿ ថវិកាចំនួន ៤.៥០០ ដុល្លារ
៤-លោក សាណាម បួរ ថវិកាចំនួន ៤.៥០០ ដុល្លារ
៥-លោក យៃ យឿន ថវិកាចំនួន ៤.០០០ ដុល្លារ
៦-លោក អ៊ិន សំណាយ ថវិកាចំនួន ៤.០០០ ដុល្លារ
៧-លោក ឈឿន សេត ថវិកាចំនួន ៤.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តព្រះវិហារ

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ និង បង្គន់អនាម័យ ចំនួន០២បន្ទប់ នៅអនុវិទ្យាល័យស្រយ៉ង់ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ សរុបទឹកប្រាក់ ចំនួន ៣៤.០០០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-លោក NAKAMURA HIROYOSHI សប្បុរសជនជប៉ុន

២-លោក NEGISHI TSUNEJI សប្បុរសជនជប៉ុន

៣-លោក MIURA KIRIVUTH សប្បុរសជនជប៉ុន

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៦៤៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនសម្តេចព្រះឧត្តមវង្សា **មួន រ៉ា** នាយកប្រតិបត្តិអភិបាលកិច្ចសង្ឃ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបរិច្ចាគនូវបច្ច័យផ្ទាល់ព្រះអង្គ ចំនួន ១០.២៨៨ ដុល្លារអាមេរិក សម្រាប់ជួយធ្វើរបង ខ្លោងទ្វារ ផ្តល់តុ-កៅអីសិស្ស ចំនួន ២១០ កុំព្យូទ័រ ០១គ្រឿង មេក្រូ ០១គ្រឿង សៀវភៅសរសេរ ៣.០០០ ក្បាល ប៊ិចសរសេរ ៣.០០០ ដើម សៀវភៅពន្លឺពុទ្ធសាសនា ១០ក្បាល និងកែលំអទីចាត់ការ នៅសាលាបឋមសិក្សាព្រែកព្នៅ ក្នុងស្រុកពញាឮ ខេត្តកណ្តាល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៥៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព លោក BALA CHANDRAN ជនជាតិម៉ាឡេស៊ី ជំនួយការខាងសារព័ត៌មានភាសាអង់គ្លេស ប្រចាំអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ដែលកន្លងមក លោកបានជួយដំណើរការការងារ នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា លើវិស័យព័ត៌មាន ភាសាអង់គ្លេសជារៀងរហូតមក ហើយបានទទួលមរណភាព ដោយជម្ងឺគាំងបេះដូង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៤១ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាសអន្តរក្រសួង
# ស្តីពីគោលការណ៍ចំណាយសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (PAP) នៅក្រសួងអប់រំ យុវជន និងកីឡា

************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស. រកត.១១៩៨. ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ០២ នស. ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស. ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេខ រកម .០១-៩៩. ០១ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីនិតិវិធីនៃការបើកផ្តល់មុន ដោយអាណត្តិបើកប្រាក់ ។

-បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១១៥ សហវ.ម. ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-សារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការប្រព្រឹត្តទៅនៃកិច្ចលទ្ធកម្ម ចំពោះក្រសួង ក្រសួង អាទិភាពទាំងបួន

ពីរ

## ខ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

១-ថវិកាសំរាប់ដំណើរការសាលារៀន

ផ្ដល់ថវិកា ដល់គ្រប់សាលាបឋមសិក្សា ចំនួនពី ៥០០,០០០រៀល -៧០០,០០០០រៀល ក្នុងមួយសាលា និងចំនួន ៧.០០០រៀល- ៨,០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សាសំរាប់ចំណាយលើ :

- សំភារៈមូលដ្ឋាន
-ការជួសជុលតូច ( សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )
-ការកែលំអបរិស្ថានសាលា និងថ្នាក់រៀន
-បំណិនជីវិត ( កីឡា សិល្បៈ រោងជាង គេហវិជ្ជា និង កសិកម្ម )
-ចំណាយសំរាប់ទឹកស្អាត និងអនាម័យ
-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
-ការរៀបចំឯកសារធ្វើតេស្តចុងឆ្នាំសិក្សា សំរាប់ថ្នាក់ទី ៣ និង ទី ៦
-ចំណាយផ្សេងៗ ។

២-ថវិកាសំរាប់ពង្រឹង គុណភាពរៀន និងបង្រៀន

-ផ្ដល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកំរងសាលារៀន( ដើមឆ្នាំ កណ្ដាលឆ្នាំ និង ចុងឆ្នាំ) ចំនួន ១១ពេល ក្នុងមួយឆ្នាំសិក្សា។

-ផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន ដែលបានបង្រៀនម៉ោងបន្ថែម សំរាប់ជួយសិស្ស នៅថ្ងៃព្រហស្បតិ៍ក្នុងឆ្នាំសិក្សា ចំនួន ១០,០០០រៀល ក្នុងមួយពេលក្នុងមួយនាក់ ដោយគិតទាំងអ្នកគ្រប់គ្រង បណ្ណារក្ស រោងជាង និងលេខាធិការ ។

## គ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

១-ផ្ដល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួនពី១,០០០,០០០រៀល-១,៥០០,០០០រៀល ក្នុងមួយសាលា ដល់គ្រប់អនុវិទ្យាល័យ និងវិទ្យាល័យ និងចំនួន ១៥.០០០រៀល - ១៨,០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ ចំណាយលើ :

- សំភារៈមូលដ្ឋាន
- ការកែលំអបរិស្ថានសាលារៀន និងថ្នាក់រៀន
- ការជួសជុលតូច ( សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )
- បំណិនជីវិត (កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម)
- ការរៀបចំឯកសារ និង សំភារៈផ្សេងៗ សំរាប់ប្រលងឆមាស

- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ចំណាយផ្សេងៗ ។

២-ផ្តល់ថវិកាសំរាប់ប្រគល់រង្វាន់សិស្សពូកែប្រចាំឆ្នាំ ចំនួន ១០០.០០០រៀលក្នុងមួយថ្នាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើសំភារៈសិក្សា។

## ឃ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការរៀបចំស្តង់ដាតេស្ត ការទទួលស្គាល់កម្មវិធីសិក្សា និង មេរៀន ដោយអញ្ជើញអ្នកបច្ចេកទេសពីស្ថាប័នផ្សេង មកជួយហើយផ្តល់ជូន ១ជំនាញមាន ០២នាក់ចំនួន ១.០០០.០០០រៀល ក្នុងមួយក៏រិត ។

## ង- បន្តការអភិវឌ្ឍគ្រូបង្រៀន

១- ផ្តល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួន ៣០.០០០.០០០រៀល ក្នុងមួយសាលាដល់ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម ចំនួនពី១០០.០០០រៀល- ១២០.០០០រៀលក្នុងគរុសិស្ស-និស្សិតមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើ :

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពអប់រំសីលធម៌ និង មនសិការវិជ្ជាជីវៈ
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពពលកម្មផលិត
- សកម្មភាពសិល្បៈ និង កីឡា
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ
- ចំណាយផ្សេងៗ:
    + សំភារៈមូលដ្ឋាន
    + ការជួសជុលតូច ( សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច)
    + ការដឹកជញ្ជូន ការផ្គត់ផ្គង់សំភារៈ ។

២ -ការរៀបចំឯកសារធ្វើតេស្ត សំរាប់វាយតម្លៃសមត្ថភាពគ្រូឧទ្ទេសត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

| | | |
|---|---|---|
| - ការកសាងតេស្ត | ឧបត្ថម្ភ | ១០០.០០០រៀល/ ១មុខវិជ្ជា |
| - ការធ្វើអត្រាកំណែ | ឧបត្ថម្ភ | ២០.០០០រៀល/ ១នាក់ |
| - កំរែកែកិច្ចការ | ឧបត្ថម្ភ | ២.០០០រៀល/ ១កិច្ចការ |
| - គណៈកម្មការបូកសរុបលទ្ធផល | ឧបត្ថម្ភ | ៥០.០០០រៀល/ ១នាក់ |
| - គណៈកម្មការត្រួតពិនិត្យ | ឧបត្ថម្ភ | ៣០.០០០រៀល/ ១នាក់ |

ssត

- អ្នកធ្វើរបាយការណ៍ ឧបត្ថម្ភ ៣០.០០០រៀល/ ១នាក់

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសេចក្តីណែនាំស្តីពីការកំណត់និយាមរៀបចំគណៈកម្មការនីមួយៗ អោយបានច្បាស់លាស់ក្នុងកិរិតអប្បបរមា ។

**ច-** ចំពោះគ្រឹះស្ថាន ឬ មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដែលចប់ការគាំទ្រទាំងផ្នែកសំភារៈ និងថវិកាពីរដ្ឋាភិបាលបរទេស ឬ អង្គការអន្តរជាតិ នឹងទទួលបានការឧបត្ថម្ភថវិកាសំរាប់ដំណើរការសាលារៀន ចំនួន ៥០.០០០.០០០រៀល ក្នុងមួយសាលា និង ចំនួន ៥០០.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សំភារៈមូលដ្ឋាន
- ការជួសជុលតូច ( សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច )
- សំភារៈកសិកម្ម រោងជាង និងបន្ទប់ពិសោធន៍
- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ចំណាយផ្សេងៗ ។

## ឆ- គុណភាព និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា

ផ្តល់ថវិកាសំរាប់ដំណើរការមជ្ឈមណ្ឌល ឬ សាលា ចំនួន ៣០.០០០.០០០រៀល ក្នុងមួយ មជ្ឈមណ្ឌល ឬសាលា និងចំនួន ១២០.០០០រៀល ក្នុងគរុសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពបច្ចេកទេស និង ប្រកួត
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រកីឡា និង វេជ្ជសាស្ត្រកីឡា
- ចំណាយផ្សេងៗៈ
  - +សំភារៈការិយាល័យ
  - +ការជួសជុលទីលាន និង សំភារៈបច្ចេកទេសហ្វឹកហាត់
  - +ការដឹកជញ្ជូន
  - +ការផ្គត់ផ្គង់
  - +ឯកសារសំរាប់ប្រជុំ។

**ជ- ការពង្រីកអប់រំក្រៅប្រព័ន្ធ :**

ផ្តល់ថវិកាសំរាប់ដំណើរការ ថ្នាក់បំប៉នសិស្សបោះបង់ការសិក្សាចំនួនពី៥០.០០០រៀល-១០០.០០០រៀល ក្នុងមួយថ្នាក់ក្នុង ១ឆ្នាំ ( ខែសីហា និងកញ្ញា ) សំរាប់ចំណាយលើ : សៀវភៅ ប៊ិច ដីស ហ្វឺតសរសេរ ក្តារខៀន ។ល ។

**ឈ- គោលការណ៍រួម និងដោយឡែកសំរាប់អនុវត្តគ្រប់កម្មវិធីសកម្មភាពជាអាទិភាព (PAP)**

ការអនុវត្តកម្មវិធី សកម្មភាពជាអាទិភាព និង ការកសាងឯកសារបង្រៀន និងរៀនត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

**១_គោលការណ៍រួម**

- ការថតចំលងឯកសារដោយមិនប្រើសំភារៈរបស់រដ្ឋ ទូទាត់ តាមតំលៃជាក់ស្តែង
- ការវាយកុំព្យូទ័រ ឧបត្ថម្ភ ១.៥០០រៀល ក្នុង១ទំព័រ
- អ្នកគូររូប ឧបត្ថម្ភ ១៦.០០០រៀល ក្នុង១ទំព័រ
- ការបកប្រែឯកសារ ឧបត្ថម្ភ ៤.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- អ្នកនិពន្ធ ឧបត្ថម្ភ ១៤.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យ ឧបត្ថម្ភ ១.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការរៀបរៀង និង ចងក្រង ឧបត្ថម្ភ ៤.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការកែលំអមេរៀន ឧបត្ថម្ភ ១២.០០០រៀល ក្នុង១មេរៀន

**២_គោលការណ៍ដោយឡែកសំរាប់អនុវត្ត នៅតាមគ្រឹះស្ថានឧត្តមសិក្សា**

- ការបកប្រែឯកសារ ឧបត្ថម្ភ ១២.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- អ្នកនិពន្ធ ឧបត្ថម្ភ ២៨.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យ ឧបត្ថម្ភ ៤.០០០រៀល ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការកែលំអមេរៀន ឧបត្ថម្ភ ២០.០០០រៀល ក្នុង១មួយមេរៀន
- ការជួលម៉ូដែល (Model) មនុស្សពិតមក

ធ្វើគំរូ សំរាប់អោយនិស្សិតគូរតាម ឧបត្ថម្ភ ២០.០០០រៀល ក្នុង១គំរូ ក្នុង១ពេល

⊗ ចំពោះការទិញសំភារៈ និងឯកសារស្រាវជ្រាវផ្សេងៗពីបរទេស ត្រូវទូទាត់តាមសក្ខីបត្រជាក់ស្តែងតាមអត្រាប្តូរប្រាក់ជាផ្លូវការរបស់ធនាគារជាតិ ( ចំពោះតែសំភារៈនិងឯកសារណាដែលគ្មានលក់លើទីផ្សារក្នុងស្រុក ) ។

៦៣៧

ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០០០ ឧ.រ.ថ.ក.ប-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៨៣ /០៥ គ.វ.ក ចុះថ្ងៃទី០២.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សំ សុង (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី១៨.១០.២០០៥

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សំ សុង(ខេមបូឌា) ខូ អិលធីឌី (SAM SONG (CAMBODIA) Co., LTD.) តំណាងដោយ លោក CHO HYUN BAEK សញ្ជាតិកូរ៉េ ភេទប្រុស អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ NW1034679 ចុះថ្ងៃទី២២.០៦.២០០៤ បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ និងបោះពុម្ព ដែលមានឈ្មោះថា"សំ សុង (ខេមបូឌា)ខូ អិលធីឌី (SAM SONG (CAMBODIA) Co., LTD.)"មានទីតាំងស្ថិតនៅ អាគារលេខ៣៣ សួនឧស្សាហកម្មកាណាឌីយ៉ា ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

## ជំពូក ៣

## នីតិវិធីលទ្ធកម្មសាធារណៈ

**ប្រការ ៣** :-គ្រប់អង្គភាពគ្រប់គ្រងថវិកា (BMC) និងអង្គភាពដែលទទួលថវិកា **PAP** មានសិទ្ធិចំណាយក្រោម **១.០០០.០០០រៀល**។

-គ្រប់អង្គភាពគ្រប់គ្រងថវិកា (BMC) នៅរដ្ឋបាលកណ្ដាល និងមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុងមានសិទ្ធិចំណាយ ចាប់ពី **១លានរៀលដល់** ក្រោម **៥លានរៀល** ដោយអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន ។

**ប្រការ ៤** : រាល់ការចំណាយចាប់ពី **៥លានរៀល**ឡើង អាណាប័កឬអាណាប័កផ្ទេរសិទ្ធិត្រូវស្នើសុំគោលការណ៍ចំណាយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រោយពីបានទទួលគោលការណ៍ចំណាយរួចត្រូវអនុវត្តនីតិវិធីតាមស្មារតី នៃប្រកាសលេខ ០៤៥ សហវ.ប្រកចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ។ រាល់ការចំណាយចាប់ពី៥លានរៀលឡើងទៅ ត្រូវមានការចូលរួមអនុវត្តដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ។

## ជំពូក៤

## អវសានបញ្ញត្តិ

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកម្មវិធីសកម្មភាពជាអាទិភាព ឆ្នាំ ២០០៦ តទៅ ។

**ប្រការ៦** : រាល់បញ្ញត្តិទាំងឡាយដែលមានចែងក្នុងប្រកាសអន្តរក្រសួងលេខ ៥៦០ សហវ. ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ ត្រូវទុកជានិរាករណ៍។

**ប្រការ៧** : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
បណ្ឌិត គុល ប៉ាញ

**កន្លែងទទួល**:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
  "ដើម្បីជូនជ្រាប"
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ "ដើម្បីអនុវត្ត" "ដើម្បីមុខការ"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០០០ ឧស្ស.រ៉ែ.ថព.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៨៣ /០៥ គ.វ.ក ចុះថ្ងៃទី០២.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សំ សុង (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី១៨.១០.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សំ សុង(ខេមបូឌា) ខូ អិលធីឌី (SAM SONG (CAMBODIA) Co., LTD.) តំណាងដោយ លោក CHO HYUN BAEK សញ្ជាតិកូរ៉េ ភេទប្រុស អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ NW1034679 ចុះថ្ងៃទី២២.០៦.២០០៤ បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ និងបោះពុម្ព ដែលមានឈ្មោះថា"សំ សុង (ខេមបូឌា)ខូ អិលធីឌី (SAM SONG (CAMBODIA) Co., LTD.)"មានទីតាំងស្ថិតនៅអាគារលេខ៣៣ សួនឧស្សាហកម្មកាណាឌីយ៉ា ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់ និងបោះពុម្ព " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន សំ សុង(ខេមបូឌា) ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
Nº ១០០១ ឧស៥-ករ-ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៩០៨/០៥ គ.វ.ក ចុះថ្ងៃទី ៣០.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ី អេស ហ្គាមេន ចុះថ្ងៃទី០៧.១១.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី អេស ហ្គាមេន ( E S GARMENT CO., LTD.)តំណាងដោយលោក HENG KHENG AIK សញ្ជាតិសឹង្ហបូរី អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S1121718D ចុះថ្ងៃទី២៨.០៥.១៩៩៨ បង្កើតរោងចក្រ“កាត់ដេរសម្លៀកបំពាក់”ដែលមានឈ្មោះថា “ អ៊ី អេស ហ្គាមេន ( E S GARMENT )” មានទីតាំងស្ថិតនៅ ឃ្លាំងលេខK៤ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

<u>ប្រការ២:</u> ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

<u>ប្រការ៣:</u> រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤:</u> ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥:</u> ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦:</u> ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧:</u> ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨:</u> ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩:</u> អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ៊ី អេស ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

<u>ប្រការ១០:</u> ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

<u>ចម្លងជូន :</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១០០៦៧ ឧរ៥.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៩០៩/០៥ គ.វ.ក ចុះថ្ងៃទី ៣០.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្គូលដេន ប្រូហ្វិត (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី ១៨.១១.២០០៥

# សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គូលដេន ប្រូហ្វិត (ខេមបូឌា) ហ្គាមេន (GOLDEN PROFIT (CAMBODIA) GARMENT CO., LTD.) តំណាងដោយលោក LO WAI LUN សញ្ជាតិចិន អាយុ៤២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H01270719 ចុះថ្ងៃទី១០.០៨.២០០០ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហ្គូលដេន ប្រូហ្វិត (ខេមបូឌា) ហ្គាមេន ( GOLDEN PROFIT (CAMBODIA) GARMENT )"មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ ភូមិជិពូវន្ត័ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហ្គូលដេន ប្រូហ្វីត (ខេមបូឌា) ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០១៤ ឧ.រ.ថ.ក.ន-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ២០០៥

# ប្រ ក ា ស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៨៨៩/០៥ គ.វ.ក ចុះថ្ងៃទី ២៨.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អេសប៊ីអិម-ស៊ីជី ចុះថ្ងៃទី១៥.០៩.២០០៥

# ស ំ រ េ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេសប៊ីអិម-ស៊ីជី (SBM-CG., LTD) តំណាងដោយលោក ភោគ សំអឿន សញ្ជាតិខ្មែរ អាយុ៣៣ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010148462 ចុះថ្ងៃទី០១.១០.២០០១ **បង្កើតរោងចក្រ "ផលិតម្សៅជំឡូងមី"** ដែលមានឈ្មោះថា " **អេសប៊ីអិម-ស៊ីជី** (SBM-CG.,LTD) " មានទីតាំងស្ថិតនៅ ភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្ដល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Bculevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

**ក. អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម**

**១ . នាយកដ្ឋានការពារផ្លូវច្បាប់ មាន ០៤ ការិយាល័យ :**

- ការិយាល័យផ្នែកច្បាប់
- ការិយាល័យទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- ការិយាល័យទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ
- ការិយាល័យទប់ស្កាត់ការរំលោភផ្លូវភេទ

**២ . នាយកដ្ឋានស្ត្រី និងសុខភាព មាន ០៤ ការិយាល័យ :**

- ការិយាល័យលើកកម្ពស់សុខភាពបន្តពូជ
- ការិយាល័យលើកកម្ពស់អាហារូបត្ថម្ភ
- ការិយាល័យបង្ការជំងឺអេដស៍
- ការិយាល័យបង្ការជំងឺផ្សេងៗ

**៣ . នាយកដ្ឋានស្ត្រី និងការអប់រំ មាន ០៤ ការិយាល័យ :**

- ការិយាល័យគ្រប់គ្រងអន្តេវាសិកដ្ឋានសិស្សស្រី
- ការិយាល័យលើកកម្ពស់ការអប់រំស្ត្រី និងកុមារី
- ការិយាល័យអប់រំបំនិនជីវិត
- ការិយាល័យអប់រំកុមារតូច

**ប្រការ ២** : តួនាទី ភារកិច្ចជាក់ស្តែងរបស់ការិយាល័យនីមួយៗ អាស្រ័យដោយនាយកដ្ឋានសាមីរៀបចំឡើង និងលើក សំណើជូនរដ្ឋមន្ត្រីពិនិត្យ សំរេច ក្រោយពីបានការឯកភាពពីអគ្គនាយកដ្ឋានរបស់ខ្លួន ។

**ប្រការ ៣** : ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤** : បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានក្រោមឱវាទក្រសួងត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ១៩៤៧

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

រដ្ឋមន្ត្រីស្តីទី

ឃឹម-ចំរើន

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៥
- ឯកសារ -កាលប្បវត្តិ

- ការិយាល័យបូកសរុប
- ការិយាល័យបៀវត្ស -ពលកម្ម

**២. នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មាន ០៥ ការិយាល័យ :**

- ការិយាល័យគ្រប់គ្រងថវិកា
- ការិយាល័យគណនេយ្យ
- ការិយាល័យបេឡា
- ការិយាល័យសំភារៈ និងផ្គត់ផ្គង់
- ការិយាល័យគ្រប់គ្រងមូលនិធិអន្តរជាតិ

**៣. នាយកដ្ឋានផែនការ និងស្ថិតិ មាន ០៤ ការិយាល័យ :**

- ការិយាល័យផែនការ និងរបាយការណ៍
- ការិយាល័យតាមដានគំរោង
- ការិយាល័យស្ថិតិ
- មជ្ឈមណ្ឌលព័ត៌មានស្ត្រី ( ថ្នាក់ស្មើការិយាល័យ )

**៩. អគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច**

**១ . នាយកដ្ឋានព័ត៌មាន មាន ០៤ ការិយាល័យ :**

- ការិយាល័យស្រាវជ្រាវ និងផលិតព័ត៌មាន
- ការិយាល័យផ្សព្វផ្សាយតាមវិទ្យុ
- ការិយាល័យផ្សព្វផ្សាយតាមទូរទស្សន៍
- ការិយាល័យបោះពុម្ពផ្សាយ

**២ . នាយកដ្ឋានសមភាពយេនឌ័រ មាន ០៤ ការិយាល័យ :**

- ការិយាល័យគោលនយោបាយ
- ការិយាល័យរបាយការណ៍ជាតិ
- ការិយាល័យអភិបាលកិច្ចមូលដ្ឋាន
- ការិយាល័យស្ត្រីក្នុងតួនាទីធ្វើសេចក្តីសំរេច

**៣ . នាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច មាន ០៤ ការិយាល័យ :**

- ការិយាល័យឥណទាន
- ការិយាល័យពង្រីកឱកាសការងារស្ត្រី
- ការិយាល័យកែច្នៃផលិតផល
- ការិយាល័យអភិវឌ្ឍជំនួញខ្នាតតូច-មធ្យម ១៩៤០៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង កិច្ចការនារី

លេខ ...១.១០...... កកន/ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតការិយាល័យចំណុះនាយកដ្ឋាន
# ក្រោមឱវាទក្រសួងកិច្ចការនារី

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណូមពរការងារចាំបាច់ ។

## សម្រេច

ប្រការ ១ : ត្រូវបានបង្កើតការិយាល័យចំណុះនាយកដ្ឋាននានា ក្រោមឱវាទក្រសួងកិច្ចការនារីដូចមានខាងក្រោម :

**ក. អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ**

**១. នាយកដ្ឋានរដ្ឋបាល-បុគ្គលិក មាន ០៥ ការិយាល័យ :**

- ការិយាល័យរបៀប
- ការិយាល័យបុគ្គលិក
- ការិយាល័យពិធីការ ១៧៩០៧

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ“ផលិតម្សៅដំឡូងមី” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង និងប្រធានក្រុមហ៊ុន អេសប៊ីអិម-ស៊ីជី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ_សែម**

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តបាត់ដំបង
“ ដើម្បីជូនជ្រាប ”
-ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៧៣៦ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស.ធី.អូ រៀល អ៊ីស្ទេត អេន ខនស្ត្រាក់សិន**

**S. T. O REAL ESTATES AND CONSTRUCTION Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8230/05P ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សេង សុជាតិ** ប្រធានក្រុមប្រឹក្សាភិបាល

លោក **គាត សុនី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៦១ ផ្លូវលេខ ៤៣០ សង្កាត់ ទំនប់ទឹក ខណ្ឌ ចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូរសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៧៣៣ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឃែភីថល ហ្វាម៉ាស៊ី សេនធ័រ**
**CAPITAL PHARMACY CENTER Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2671/05E ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **NIELS EIKELAND**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១២.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសលក់ ឱសថ វត្ថុធាតុដើមផលិតឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់រែជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស និងសេវាចែកចាយទំនិញ

-សេវាយកក់រែជើងសារលើកដាក់ទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ច. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៣/៣៤ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តាឡា សាយអិនស៍ ថេកណូឡូជី គ្រុប**
TALA SCIENCE TECHNOLOGY GROUP Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2670/05E ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី XU XIUHUA

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៧ Eo. ផ្លូវលេខ ១៣៦ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសថ្នាំសំលាប់សត្វល្អិត វត្ថុធាតុគីមីបំរើអោយវិស័យកសិកម្ម សំភារៈបរិក្ខារអគ្គីសនីនិងអេឡិចត្រូនិក សំភារៈបរិក្ខារសំណង់ គ្រឿងសំអាង នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យ អាហារថែទាំនិងបំប៉នសុខភាព កសិផល ជលផលគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងទទួលទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៣៤ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ជីនផាន ធានហ្វ័រ**
**JINPAN TENFORE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8232/05P ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥**

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី LIN SU, HSIU - YU ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី CHOU, CHING - TING អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៨៨ ភូមិ CPC សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង អចលនៈទ្រព្យ គ្រឿងចក្រ សំណង់ផ្សារទំនើប ទិញ លក់ ជួលបញ្ចាំមូលនីធិពាណិជ្ជកម្ម
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក់រៃដើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងផ្នែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
គីម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៣៦ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **យ៉ាគីន ប៊ីលីហ្វ អ៊ិនវេសមេន**

**YAKIN BELIEF INVESTMENT Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8227/05P ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក BUDY SANTOSO TJOE ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ខែម សុផានី** អភិបាល

លោកស្រី **អ៊ឹម សុផា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៧A ផ្លូវលេខ ២៧២ ក្រុមទី២៩ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-អភិវឌ្ឍន៍ដីធ្លី

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ

-ពិសេសនាំចេញនាំចូលនិងលក់សំភារៈបរិក្ខារសំណង់

នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៧៤០ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដាប់ប៊ែលយូ អិល អេច ស៊ី (ខេមបូឌា) លីមីធីត**

**WLHC ( Cambodia ) Limited**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8234/05P ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **DAVID ANDREW CHEESEMAN** "តតីយជន" អភិបាល

លោកស្រី **MELISSA KAY SPINOCCHIA** "តតីយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥ ផ្លូវ ព្រះសុរាម្រិត សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល ផលិត សេវាយកកំរៃជើងសារ ដឹកជញ្ជូននិងសេវាផ្សេងៗទៀត ទាក់ទងនិងអចលនទ្រព្យ

-ប្រកបអាជីវកម្មផ្នែកអភិវឌ្ឍន៍ និងវិនិយោគអចលនទ្រព្យ

-ប្រតិបត្តិការផ្នែកសណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត និងសកម្មភាពផ្សេងទៀតដែលទាក់ទង នឹងវិស័យទេសចរណ៍

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

ព្រះរាជាណាចក្រកម្ពុជា ក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថន

**ចំលងជូន**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce

លេខ ២៧៤២ ពណ.នតក

ភ្នំពេញថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ិនហ្វីនិធី ស៊ីបផ្លាយ**

**INFINITY SUPPLY Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8235/05P ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **យិន ឌន** ប្រធានក្រុមប្រឹក្សាភិបាល

លោក **NIWAT ANTHARABUT** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៩៣ ភូមិ ២ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។

៥- កម្មវត្ថុអាជីវកម្ម : -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ កំពង់ផែ ផ្លូវដែក អាកាសយានដ្ឋាន

-សិក្សាគំរោងប្លង់និងគូរប្លង់គ្រប់ប្រភេទ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហារណទំនិញគ្រប់ប្រភេទ

-ពិសេសនាំចូលកៅស៊ូក្រាលថ្នល់ ប្រេងឥន្ធនៈ សំភារៈបរិក្ខារសំណង់ និងគ្រឿងចក្រគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

